ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការគ្រប់គ្រងចំការស្វាយចន្ទី




រៀបចំដោយ **នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម**

សហការជាមួយ **សាកលវិទ្យាល័យភូមិន្ទកសិកម្ម**



ឧបត្ថម្ភដោយ **គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី**

**រៀបរៀងដោយ លោក ឃួន អៀង**

**លោក ស៊ីប បញ្ញាសុឡី**

**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

ទូរស័ព្ទ:   ០១២៩១៨៧៨៤/០១២ ៨៣០៣១២

**អ៊ីម៉ែល:** pagnasoley@yahoo.com

eang_467@hotmail.com

**កាលបរិច្ឆេទ: ខែ សីហា ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាះ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹង សមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្មការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជា បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង ។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត ។ ឯកសារដ៏មានសារៈ សំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ ប្រជាកសិករ និងផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្ម កសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រស្រប តាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និង ទទួលបានផ្លែផ្កាល្អប្រសើរប្រកប ដោយក្តីសង្ឃឹម ។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យាដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុកនិងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាលនិង ផ្នែកផ្សេងៗ ទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍ កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់ ។ បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈ ប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មាន សំខាន់ៗរបស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធ កៀស្រត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប មាននៅតាមស្ថាប័ន នានាដូចខាងក្រោម:

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា ។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុម ការងារ បអប បន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទសម្រាប់ប្រើប្រាស់ នៅតាមមូលដ្ឋាន ។

# ការគ្រប់គ្រងចំការស្វាយចន្ទី


**១ សេចក្ដីផ្ដើម** ........ **១**

**២ គោលការណ៍បច្ចេកទេស** ........ **២**

២.១ លក្ខណៈរូបសាស្ត្ររបស់ដំណាំស្វាយចន្ទី ........ ២

២.២ លក្ខណៈជីវសាស្ត្ររបស់ដំណាំស្វាយចន្ទ ........ ៤

**២.២.១ ដំណាក់កាលដុះពន្លក** ........ **៤**

**២.២.២ ដំណាក់កាលរីកលូតលាស់** ........ **៤**

**២.២.៣ ដំណាក់កាលចេញផ្កា** ........ **៥**

**២.២.៤ ដំណាក់កាលពេញវ័យ និងផ្លែ** ........ **៥**

**២.២.៥ តំរូវការបរិស្ថាន** ........ **៥**

២.៣ ប្រភេទពូជ ........ ៦

២.៤ គំរោងប្រព័ន្ធដំណាំចំរុះ ........ ៧

**២.៤.១ ចន្លោះរង និង ដើម** ........ **៧**

**២.៤.២ ដំណាំចន្លោះរង ឬ ចន្លោះជួរ** (Intercropping) ........ **៧**

**២.៤.៣ ការដាំដំណាំគំរបដី** ( Cover Cropping ) ........ **៨**

២.៥ បច្ចេកទេសដាំដុះដំណាំស្វាយចន្ទី ........ ៨

**២.៥.១ ការរៀបចំចំការដាំស្វាយចន្ទី** ........ 8

**២.៥.២ ការរៀបចំដី** ........ **៩**

**២.៥.៣ ការជីករណ្ដៅ** ........ **៩**

**២.៥.៤ ការដាំដុះ** ........ **១០**

**២.៥.៥ ការបោះបង្គោលជាប់កូនឈើ និងគំរបដី** ........ **១៣**

**២.៥.៦ ការកាត់មែកស្វាយចន្ទី ( ចំពោះដើមដាំដោយគ្រាប់ តត្រួយ និង សាក)** ........ **១៣**

២.៦ ការអភិរក្ស ដី និងទឹក ........ ១៣

២.៧ ការការពារកត្តាចង្រៃ ........ ១៤

**២.៧.១ ជំងឺ** ........ **១៥**

**២.៧.២ សត្វល្អិតចង្រៃ** ........ **១៧**

**២.៧.៣ ស្មៅចង្រៃ** ........ **២១**

**២.៧.៤ ការការពារភ្លើង** ........ **២១**

២.៨ ការប្រើប្រាស់ជី ........ ២១

**២.៨.១ ជីកំប៉ុស្ដិ៍** ........ **២១**

**២.៨.២ ជីគីមី** ........ **២២**

២.៩ ការប្រមូលផល និងការកែច្នៃគ្រាប់ស្វាយចន្ទី ........ ២៣

**២.៩.១ ការប្រមូលផល** ........ **២៣**

**២.៩.២ បច្ចេកទេសបកសំបកគ្រាប់ស្វាយចន្ទី** ........ **២៣**

២.១០ ការស្តុកផលិតផលស្វាយចន្ទី ........ ២៨

២.១១ បច្ចេកទេសនៃការបកសំបក ការថែរក្សា និង ការស្តុកគ្រាប់ស្វាយចន្ទីសខ្ចប ........ ៣០

២.១២ ការកែច្នៃ ........ ៣៣

២.១៣ ការពង្រីកពូជស្វាយចន្ទី ........ ៣៤

**ការជ្រើសរើសពូជដែលមានទិន្នផលខ្ពស់........ Error! Bookmark not defined.**

**ការបន្តពូជតាមសិរីរាង្គលូតលាស់ ........ Error! Bookmark not defined.**

**បច្ចេកទេសត្រួយលើដើមចាស់ ........ Error! Bookmark not defined.**

២.១៤ សេដ្ឋកិច្ច........ ៣៨

**ការប្រែប្រួលតំលៃលើទីផ្សារ ........ Error! Bookmark not defined.**

**តំលៃគ្រាប់ស្វាយចន្ទី........ Error! Bookmark not defined.**

**ការប្រៀបធៀបសេដ្ឋកិច្ចរវាងការដាំតាមទំលាប់ និងប្រើតាមបច្ចេកទេស ........ ៣៩**

**៣. ការកំណត់តំបន់សម្រាប់ផ្សព្វផ្សាយ(ការផ្សាំ និង បំបៅ)........ ៣៩**

៣.១ អ្នកដែលត្រូវបណ្តុះបណ្តាល........ ៣៩

៣.២ ចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាលក្នុង១ វគ្គ ........ ៤០

៣.៣ សំភារៈសម្រាប់ចំណាយក្នុងការបណ្តុះបណ្តាល និង ការអនុវត្តន៍........ ៤០

៣.៤ ពេលវេលា........ ៤០

៣.៥ ផែនការវគ្គបណ្តុះបណ្តាល ........ ៤០

៣.៦ ការចំណាយទៅលើសំភារៈ និងការចំណាយផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាល ........ ៤១

៣.៧ សកម្មភាពត្រួតពិនិត្យ និង វាយតំលៃ........ ៤២

# ដំណាំស្វាយចន្ទី

## ១ សេចក្តីផ្តើម

**សេចក្តីសង្ខេប**

***បញ្ហា***

-កសិករដែលដាំស្វាយចន្ទីពុំមានបច្ចេកទេសគ្រប់គ្រាន់ក្នុងការគ្រប់គ្រងចំការ

-កសិករទទួលបានទិន្នផលស្វាយចន្ទីទាប

-ពុំមានឯកសារបច្ចេកទេសអនុវត្តស្វាយចន្ទីសម្រាប់ការអនុវត្តន៍

***គោលដៅ*** បង្កើនទិន្នផល និង ប្រាក់ចំណូលប្រជាជនដែលដាំស្វាយចន្ទី

***វិធីសាស្ត្រ***

-កែលំអក្នុងការគ្រប់គ្រងចំការ(ចន្លោះដើម, តាក់តែងមែក និង ការគ្រប់គ្រងសំណើម)

-ចេះពង្រីកពូជ និង ការជ្រើសរើសពូជតាមរយៈសង្កេត និង តាមដាន

-ការគ្រប់គ្រងកត្តាចង្រៃ (សត្វល្អិត, ជំងឺ និង លក្ខណៈអាកាសធាតុ)

ស្វាយចន្ទីមានឈ្មោះវិទ្យាសាស្ត្រ *Anacardium occidentale* L. ស្ថិតនៅក្នុងគ្រួសារ *Anacardiaceae* ឈ្មោះជាភាសាអង់គ្លេស Cashew ។

ប្រទេសកម្ពុជា គឺជាប្រទេសមួយ ដែលមានសក្តានុពលយ៉ាងខ្លាំងក្នុងការធ្វើផលិតកម្មគ្រាប់ស្វាយចន្ទី ម្យ៉ាងទៀតដំណាំស្វាយចន្ទីគឺជាដំណាំផ្តល់អត្ថប្រយោជន៍ដ៏ច្រើន។ ក្រៅពីសាច់គ្រាប់ដែលគេបានយកទៅបកសំបកហើយលីងសម្រាប់ក្លែមធ្វើម្ហូបអាហារផ្សេងៗនោះ ផ្លែវាគេអាចយកទៅកែច្នៃធ្វើជាអាហារបានច្រើនថែមទៀតផង ដូចជា ទឹកផ្លែឈើ ដំណាប់ ទឹកខ្មេះ និងទទួលទានផ្ទាល់តែម្តងក៏បាន។

ដំណាំស្វាយចន្ទីជាដំណាំងាយស្រួលក្នុងការដាំដុះ សមស្របទៅនឹងកសិករកម្ពុជាយើង ដែលអាចធ្វើការដាំដុះតាមលក្ខណៈធម្មតា ក៏អាចដុះបានល្អដែរ។ គេអាចធ្វើការដាំដុះពីដើមរដូវដល់ចុងរដូវប្រាំង ដោយមិនចាំបាច់ស្រោចទឹកក៏វាអាចរស់បានដែរ ម្យ៉ាងទៀតគុណសម្បត្តិដ៏ល្អប្រសើរនោះគឺអាចដាំនៅលើដីគ្រប់ប្រភេទ លើកលែងតែដីលិចទឹកប៉ុណ្ណោះ។

តំបន់សំខាន់ដែលផលិតស្វាយចន្ទី និង ដាំដុះស្វាយចន្ទីនៅក្នុងកម្ពុជា គឺស្ថិតនៅតាមបណ្តាខេត្តមួយចំនួនដូចខាងក្រោមនេះសុទ្ធតែមានផ្ទៃដីធំៗដូចជា ៖

-ខេត្តកំពង់ចាម ជាខេត្តដែលដាំច្រើនជាងគេ (ជាពិសេសតំបន់ ស្រុកមេមត់ និង ស្រុកចំការលើ)។

-ខេត្តរតនៈគីរី

-ខេត្តកំពង់ធំ(ជាពិសេសតំបន់សន្ទុក)

-ខេត្តកំពត,ខេត្តកោះកុង និងខេត្តកំពង់ស្ពឺ ខេត្តទាំងនេះផ្ទៃដីដាំដុះមានទំហំខុសៗគ្នា ហើយមានការដាំដុះកើនឡើងដែរ។

-ខេត្តមណ្ឌលគីរី, ខេត្តសៀមរាប និង ខេត្តក្រចេះ កំពុងតែបន្ថែមការដាំដុះ។

ដោយសារស្វាយចន្ទីនៅប្រទេសកម្ពុជាមានតំលៃខ្ពស់ និង មានភាពចាំបាច់នៅក្នុងទីផ្សារ គេចែកលក្ខណៈនៃទំហំចំការស្វាយចន្ទីជា ៤ប្រភេទ:

-ពួកអន្តោប្រាមឬពួកជនជាតិដែលអនុវត្តន៍កសិកម្មពនេចរនៅតាមតំបន់ខ្ពង់រាប ដោយដាំស្វាយចន្ទីជាប្រព័ន្ធដំណាំឆ្លាស់(កសិ-រុក្ខកម្ម)ប្រជាជនទាំងនោះមិនចំណាយទុនលើផលិតកម្មទេ ដោយដីមានគុណភាពល្អ (ដីបាសាល់) ចំពោះកត្តាចង្រៃដែលសំខាន់ ក៏មិនសូវមានគ្រោះថ្នាក់ ហើយក៏គ្មានវិធានការការពារដែរ ។

-ប្រជាជនធម្មតាដែលមានចំការស្វាយចន្ទីលក្ខណៈខ្នាតតូច ១-៥ ហិកតា (ភាគច្រើន ៣ ហិកតា) ដោយអនុវត្តន៍ដាំជាលក្ខណៈដំណាំចំរុះ ឈើហូបផ្លែ, និងឈើយកម្លប់... ។

-ពួកពាណិជ្ជកររដែលមានទំហំផ្ទៃដី ៥-៤០ ហិកតា(ភាគច្រើន ១៥ ហិកតា) អនុវត្តន៍នៅក្នុងកសិដ្ឋាន ឬចំការដោយប្រើគ្រឿងយន្ត ហើយមានការប្រើប្រាស់ថ្នាំពុលគីមីច្រើនក្នុងការការពារ និង កំចាត់កត្តាចង្រៃ។ កសិករប្រភេទនេះគេដឹងតំលៃពិតប្រាកដនៅតាមទីផ្សារ និង គេអាចរៀបចំជាសហគមន៍ផងដែរ ។

-ជាប្រភេទទី ៤ ដែលមានផ្ទៃដីចំការធំជាងធម្មតា ប្រហែលជា ១០០ ហិកតា ប៉ុន្តែមាននៅតំបន់ស្ទួន់ ខេត្តកំពង់ចាម មានរហូតដល់ ២.០០០ ហិកតា តែមានម្ចាស់ប្រហែលជា ១០ នាក់ ដែលមានដាំរួមគ្នាដោយបែងចែកជាឡូតិ៍ៗដាច់គ្នា ។ ប៉ុន្តែដីនេះជាដីសម្បទានរបស់រដ្ឋដែលមានការចុះកិច្ចសន្យាជាមួយរដ្ឋ(ការគ្រប់គ្រងមានកំណត់) ។

ដោយសារដំណាំស្វាយចន្ទីងាយដាំ ដូច្នេះហើយទើបមិនត្រូវការចំណាយដើមទុនច្រើនក្នុងការដាំដុះ រីឯផលិតផលវាមានតំលៃខ្ពស់ ព្រមទាំងពុំទាន់មានបញ្ហាចោទលើទីផ្សារនៅឡើយ ។ ទិន្នផលស្វាយចន្ទីនៅប្រទេសកម្ពុជាយើងជាមធ្យម ៣០.០០០- ៥០.០០០ តោនក្នុងមួយឆ្នាំ (ំចណា ុងហតៀន & Associates, 2006) ។

បច្ចុប្បន្នដំណាំស្វាយចន្ទី ជាដំណាំមួយដែលផ្តល់កំរៃខ្ពស់ ចំពោះកសិករកម្ពុជា ដូច្នេះហើយទើបថ្មីៗនេះមានការដាំដុះជាច្រើនកន្លែង ម្យ៉ាងទៀតនៅដំណាក់កាលបីឆ្នាំដំបូង គេអាចដាំដំណាំមួយចំនួននៅចន្លោះដើមស្វាយចន្ទីបាន ដូចជាសណ្តែកសៀង សណ្តែកបាយ ពោតជាដើម។ ដូច្នេះឃើញថា ដំណាក់កាលដំបូងយើងអាចទទួលផលពីផ្ទៃដី ដើម្បីរំលោះទុនលើការចំណាយដាំស្វាយចន្ទីបានខ្លះដែរ ។

## ២ គោលការណ៍បច្ចេកទេស

### ២.១ លក្ខណៈរូបសាស្ត្ររបស់ដំណាំស្វាយចន្ទី

#### ក. ស្លឹក

ស្លឹកស្វាយចន្ទី ជាប្រភេទស្លឹកឆ្លាស់គ្នា មានពណ៌បៃតង រាងទ្រវែង និង រមូលខាងចុងដូចស្លឹកប៉ោមដែលមានបណ្តោយពី ១០-១២ ស.ម និង ទទឹង ៥-៥,៧ ស.ម មានសរសៃទ្រនុងអណ្តែតចេញពីផ្ទៃស្លឹក មានក្លិនប្រហើរមានឆ្នូតពណ៌ស៊ីជំពូ ឬក្រហមចាស់ អាស្រ័យទៅតាមពូជ ។

#### ខ. ដើម

ស្វាយចន្ទីជារុក្ខជាតិឱ្យកូទីលេដុង ដែលដើមមានកំពស់ពី ៦-១២ ម៉ែត្រ និង មានអង្កត់ផ្ចិតពី ៣០,៤៦ ទៅ ៩១,៤៥ ស.ម ។ ដើមស្វាយចន្ទីបែកមែកសាខា ដែលអង្កត់ផ្ចិតនៃការបែកមែកមានពី ៤-១២ ម៉ែត្រ មានបែក

ខ្នែងជាច្រើន និង មានមែកតូច១ជាច្រើនដុះចេញពីមែកជាប់ដើម ។ បើទុកអោយវាដុះតាមលក្ខណៈធម្មជាតិដោយមិនបានតាក់តែងមែកនោះ នឹងមានបែកខ្នែងច្រើនតែបើយើងធ្វើការតាក់តែងមែកនោះ នឹងទទួលបាននូវខ្នែងដែលយើងចង់បាន ។

ដើមរបស់វាមានសាច់ឈើរឹងមធ្យម និង មានសំបកពណ៌ត្នោតប្រផេះ នៅក្នុងសំបកមានជ័រពណ៌សហើយនៅពេលត្រូវនឹងអាកាសធាតុខាងក្រៅវាប្តូរទៅជាពណ៌ខ្មៅ សាច់ឈើមានពណ៌ប្រផេះទៅពណ៌ត្នោតក្រហមនៅក្នុងសាច់ឈើមានជ័រពណ៌លឿង ដែលមានរសជាតិភ្លាវ ហើយជ័រនេះនឹងអាចប្រើជាប្រយោជន៏ជាច្រើនដូចជាថ្នាំកែរោគ ចំរាញ់ធ្វើជាជ័រ ផ្សំធ្វើថ្នាំពណ៌ និងធ្វើទឹកខ្មៅ ។

### គ. ឫស

គេនិយមដាំស្វាយចន្ទីដោយគ្រាប់ ដូច្នេះហើយបានជាឫសវាបានចាក់ចូលក្នុងដីរៅជីពី ៣ - ៤ ម៉ែត្រ ហើយដោយចាក់មកផ្ទៃខាងបានប្រវែង ២-៣ ម៉ែត្រ ។ ប៉ុន្តែក្នុងការកែលំអពូជ អោយកាន់តែប្រសើរ គឺភាគច្រើនគេច្រើនធ្វើការផ្សាំ និង បំបៅស្វាយចន្ទី មុននឹងយកវាទៅដាំដុះនៅក្នុងចំការ ។ ចំពោះការដាំដោយការផ្សាំ ឫស របស់វាចាក់ចុះទៅក្នុងដីបានរាក់ដែលមានប្រវែង ២-៣ម៉ែត្រ និង ចាក់ទៅផ្ទៃខាងបានប្រវែង ១-២ម៉ែត្រ ប៉ុណ្ណោះ រីឯការដាំដោយបំបៅវិញ គឺវាមានលក្ខណៈប្រហាក់ប្រហែលនឹងការដាំដោយគ្រាប់ ។

### ឃ. ផ្កា

កញ្ចុំផ្កាស្វាយចន្ទីមានលក្ខណៈជាចង្កោម មានទ្រង់ទ្រាយប្រហែលផ្កាស្វាយដែរ ។ ស្វាយចន្ទីចេញផ្កាចាប់ ពីអាយុ ២ ឆ្នាំឡើងទៅ ផ្កាវាចេញនៅតាមចុងមែក មានលក្ខណៈជាចង្កោម ដែលក្នុងមួយចង្កោម១មានផ្កាឈ្មោល និងផ្កាទ្វេរភេទ ។ នៅក្នុងមួយចង្កោមផ្កា មានឈ្មោលប្រមាណ ៧៥ ភាគរយ និង ផ្កាទ្វេរភេទ ២៥ ភាគរយ ។

ផ្កាឈ្មោលមាន ត្របកផ្កាចំនួន ៥ មានថង់កេសរចំនួន ៤-១០ ហើយនៅក្នុងថង់នោះមានគ្រាប់លំអងច្រើនមានពណ៌ស៊ីជំពូ នៅពេលគ្រាប់លំអងចាស់វាប្តូរទៅជាពណ៌ប្រផេះ ចំណែកឯផ្កាទ្វេរភេទវិញ មានកេសរញី និងកេសរឈ្មោល ដែលមានអូវែ និងបំពង់អូវែពណ៌លឿង។ នៅពេលដំណើរលំអងរួចហើយ អូវែនឹងក្លាយទៅជាពណ៌ស៊ីជំពូ ក្រោយមកអូវែប្តូរទៅជាពណ៌លឿងព្រលែត លាយពណ៌ស។ ផ្កាទ្វេរភេទអាចទទួលលំអងពីផ្កាឈ្មោលផង និងផ្កាទ្វេរភេទផង នៅក្នុងផ្កាដើមតែមួយ ហើយមានផ្លែក្នុងអត្រា ៣ ភាគរយ នៃចំនួនផ្កាទាំងអស់ដែលមានអត្រាខ្ពស់ ជាងដំណាំឈើហូបផ្លែដទៃទៀត។ ការចេញផ្កាគឺចាប់ផ្តើមចេញពីខែធ្នូ ដល់ចុងខែមករា ចំពោះពូជស្រាល ហើយចំពោះពូជកណ្តាល និង ពូជធ្ងន់ អាចពន្យារហូតដល់ពាក់កណ្តាលខែ មិនា ទើបឈប់ចេញផ្កា។

### ង. គ្រាប់

គ្រាប់ស្វាយចន្ទី គឺឋិតនៅខាងក្រៅនៃផ្លែ។ លក្ខណៈរបស់គ្រាប់ គឺមានរូបរាងដូចជាគ្រាប់សណ្តែកឬរាងដូចតំរងនោម បែងចែកកូទីលេដុងជាពីរស្មើគ្នា។ ពេលនៅខ្ចីវាមានពណ៌ស៊ីជំពូ បន្ទាប់មកទៀតមានពណ៌បៃតង នៅពេលលូតលាស់ធំធាត់ដល់កំរិតវាប្រែទៅជាពណ៌ប្រផេះ និងពណ៌ត្នោតចាស់ ។ ជាទូទៅចាប់ពីចេញផ្ការហូតដល់ទុំមាន

រយៈពេលរហូតដល់ ៦០ថ្ងៃ ដោយបែងចែកជាដំណាក់កាលដូចតទៅ ៖

-នៅពេលរលាយចូលគ្នានៃកាម៉ែតញី និង ឈ្មោលរហូតដល់បង្កើតបានជារូបរាងគ្រាប់ ត្រូវប្រើរយៈពេល ១៥ ថ្ងៃ

-ប្រែពណ៌ពីពណ៌ស៊ីជំពូ ទៅពណ៌បៃតង មានរយៈពេល ៥ ថ្ងៃ

-បន្តមកសំបកដែលរឹងក៏ពង្រីកខ្លួនពេញលេញអស់រយៈពេល ១៥ ថ្ងៃ

-សំបកក្រៅធំធាត់ក្នុងរយៈពេល ៥ ថ្ងៃ

-រយៈពេលទុំ ២០ ថ្ងៃ

គ្រាប់មានបណ្តោយប្រមាណ ៣ ស.ម និង ទទឹងប្រមាណ ២,៥ ស.ម សំបកគ្រាប់មានកំរាស់ ២-៣ ម.ម និង មានភាពរឹង ហើយនៅក្នុងសំបកមានប្រេងដែលមានជាតិអាស៊ីតអាណាកាឌីក រហូតដល់ ៩០ភាគរយ ។

## ២.២ លក្ខណៈជីវសាស្ត្ររបស់ដំណាំស្វាយចន្ទី

ដំណាំស្វាយចន្ទី ជាដំណាំមួយប្រភេទដែលមានអាយុកាលវែង ហើយការលូតលាស់របស់វា ក៏មានច្រើនដំ-ណាក់កាលដែរ ។ ខាងក្រោមនេះជាដំណាក់កាលលូតលាស់របស់វាៈ

### ២.២.១ ដំណាក់កាលដុះពន្លក

ដំណាក់កាលនេះ គ្រាប់ស្វាយចន្ទីចាប់ផ្តើមរីកទំហំយ៉ាងខ្លាំង ដោយសារការស្រូបយកទឹក បន្ទាប់មកសំបកវាបើកចេញ ត្រង់ចំណុចដែលស្ថិតនៅក្បែរទងភ្ជាប់ជាមួយផ្លែ ។ ពន្លកឫសលេចចេញហើយចាក់ចុះក្រោមទៅក្នុងដីនោះគឺ ជាឫសកែវរបស់វា ។ បន្ទាប់មកកូនដើម និង កូទីឡេដូនទាំងពីរដុះចេញពីសំបក ងើបឡើងលើរយៈពេលនៃការដុះចេញនេះ អាស្រ័យទៅតាមអាយុរបស់គ្រាប់ ។

ចំពោះគ្រាប់ដែលគេរក្សាទុក ១ ខែ នៅរដូវភ្លៀង វាដុះពន្លកក្នុង រយៈពេលមធ្យម ១៤ ថ្ងៃ បើគេទុកវារយៈពេល ៨ ខែ វាដុះពន្លករយៈពេល ២១ថ្ងៃ ។

### ២.២.២ ដំណាក់កាលរីកលូតលាស់

-បាន ២ ខែ មានកំពស់មធ្យម ១៥ ស.ម និង ឫសកែវប្រហែល ៥០ ស.ម គេចាត់ទុកថាកូនស្វាយចន្ទីនឹងធន់ទ្រាំនៅដើមរដូវប្រាំងដំបូងនៃការដាំវា បើសិនជាឫសកែវលូតលាស់បានមួយម៉ែត្រ គេថាស្វាយចន្ទីនោះដុះហើយ ។

-បាន ៨ ខែ វាមានកំពស់ជាមធ្យម ៥០ស.ម

-បាន ២០ ខែ វាមានកំពស់ជាមធ្យម ១៤០-១៦០ ស.ម

-បាន ២ ឆ្នាំ វាមានកំពស់ ១,៨-២ ម៉ែត្រ ជួនកាល ៣ ម៉ែត្រ

### ២.២.៣ ដំណាក់កាលចេញផ្កា

ដើមស្វាយចន្ទី ដែលដាំដោយគ្រាប់ នឹង ចេញផ្កានៅអាយុ ៣ - ៥ ឆ្នាំ ។ ការចេញផ្កានេះស្ថិតនៅលើចុងត្រួយជាកញ្ចុំ ។ នៅមួយកញ្ចុំមានផ្កាប្រមាណ ២០០-១៦០០ ផ្កា ដែលមានផ្កាទ្វេរភេទ 0,៥-២៥ ភាគរយ ។ ជាទូទៅស្វាយចន្ទីតែងតែចេញផ្កា ខែធ្នូ និង ខែកុម្ភៈ ឆ្នាំខ្លះអាចចេញផ្កាមុន នេះ ឬ ក៏យូរជាងនេះ ។ ចំពោះការចេញផ្ការបស់ស្វាយចន្ទីផ្អែកលើពូជជាកត្តាសំខាន់ ៖

-ពូជស្រាល កាចេញផ្កាចាប់ផ្តើមពីចុងខែ វិច្ឆិកា រហូត ដល់កំឡុងខែ ធ្នូ

-ពូជកណ្តាល ការចេញផ្កាចាប់ផ្តើមពី កំឡុងខែ មករា ដល់ខែដើមខែកុម្ភៈ

-ពូជធ្ងន់ ការចេញផ្កាចាប់ផ្តើមពីចុងខែ កុម្ភៈ ដល់ កំឡុងខែ មីនា

ចំពោះការចេញផ្កា រហូតដល់ទុំនេះមានការប្រែប្រួលដោយសារកត្តាអាកាសធាតុ និង បរិស្ថានដែលនៅជុំវិញ ចាប់ពី ៦០ ថ្ងៃ ដល់ ៩០ ថ្ងៃ។ ជាពិសេសសីតុណ្ហភាពខ្ពស់ធ្វើឱ្យឆាប់ចេញផ្កា ។

### ២.២.៤ ដំណាក់កាលពេញវ័យ និងផ្លែ

ស្វាយចន្ទីណាដែលទទួលបានផលិតផលទាប គឺ បណ្តាលមកពីមានភាគរយផ្កាទ្វេរភេទទាប ការកាន់ផ្លែបានតិច ជ្រុះរលួយច្រើន ម្យ៉ាងទៀតមានការខុសគ្នាពី ពូជមួយទៅពូជមួយទៀត ក៏បណ្តាលអោយផលបានខុសគ្នា និងស្ថិតនៅលើប្រភពផលិតផលដែរ គឺមានគំលាតពី ៣-១០ ភាគរយ ។ ការគួបផ្សំការកាត់បន្ថយការជ្រុះរលួយផលិតផលហើយអាចបន្ថែមទិន្នផលដោយប្រើ ២,៤-ឌុ (២,៤ ដេ ជាថ្នាំសំលាប់ស្មៅផង និង ជាអ័រម៉ូនផងក្នុងអត្រា ១០ ppm បាញ់ ទៅលើកញ្ចុំផ្កា និង នៅពេលចេញផ្កាស្រុះ និង អាចបន្ថែមទិន្នផលគ្រាប់ច្រើនជាង ២-៣ ដង។ ប្រើ NAA (អិន អេ អេ ជាអ័រម៉ូនក្នុងអត្រា ១០ ppm ប្រើពីរដងបាញ់ទៅក្នុងកញ្ចុំផ្ការីក និង អាចធ្វើអោយកាន់ផ្លែបន្ថែមច្រើនជាង ១០០ភាគរយ ។

### ២.២.៥ តំរូវការបរិស្ថាន

ភ្លៀង និង សីតុណ្ហភាព គឺ ជាភាពចាំបាច់ណាស់ សម្រាប់ការបង្កើនផលិតផលស្វាយចន្ទី ។ នៅរដូវក្តៅដែលមានមេឃស្រលះល្អ និង មានពន្លឺចាំងគ្រប់គ្រាន់ក្នុងកំឡុងពេលរដូវចេញផ្កា និង ដំណាក់កាលចេញផ្លែ វាផ្តល់ទិន្នផលល្អ ក្នុងពេលប្រមូលផល ។

#### ក.សីតុណ្ហភាព

ចំពោះស្វាយចន្ទី មិនត្រូវការអាកាស ធាតុក្តៅពេក ឬត្រជាក់ពេកទេ ។សីតុណ្ហភាពអាចស្ថិតនៅចន្លោះពី ២០ អង្សារសេ ទៅ ៣៦ អង្សារសេ ។

#### ខ.ពន្លឺ

ដំណាំស្វាយចន្ទីជារុក្ខជាតិត្រូវការពន្លឺព្រះអាទិត្យ និង មិនត្រូវការម្លប់ច្រើនទេ។ ស្វាយចន្ទីត្រូវការពន្លឺជាចាំបាច់នៅពេលចេញពន្លក និង ចេញផ្លែ។ នៅក្នុងលក្ខខណ្ឌធម្មតា ស្វាយចន្ទីត្រូវការពន្លឺទាបបំផុតពី ២,០០០-២,៤០០ ម៉ោង ក្នុងមួយឆ្នាំ តែក្នុងដំណាក់កាលចេញផ្កា និង ផ្លែ ស្វាយចន្ទីត្រូវការពន្លឺ ១,២៨៥ ម៉ោង (វិច្ឆិកា ដល់ មីនា) ។

**គ.ទឹកភ្លៀង**

ការដាំដុះស្វាយចន្ទីដែលទទួលបានជោគជ័យ ភាគច្រើនទទួលបានទឹកភ្លៀង ៥ ខែ និង លទ្ធភាពនៃការស្រូបទឹកទុករបស់ដីបានល្អ។ ជាទូទៅដំណាំស្វាយចន្ទីអាចដាំបាននៅតំបន់ដែលមានភ្លៀងធ្លាក់ពី ៥០០ ម.ម ទៅ ៤,០០០ ម.ម ក្នុងមួយឆ្នាំ (តំបន់ដែលមានភ្លៀងធ្លាក់តិច ៥០០ ម.ម ក្នុងមួយឆ្នាំ និង តំបន់ដែលមានភ្លៀងធ្លាក់ច្រើន ៣,០០០ ទៅ ៤,០០០ ម.ម ក្នុងមួយឆ្នាំ)។ ស្វាយចន្ទីមិនសូវត្រូវការទឹកពី ៤ ទៅ ៥ ខែ គឺនៅដំណាក់កាលចេញត្រួយ និង ចេញផ្លែ។

**ឃ.សំណើមបរិយាកាស**

ស្វាយចន្ទីអាចធន់ទ្រាំ នឹងតំបន់ដែលមានសំណើមបរិយាកាសទាប ដែលមានរយៈពេលវែងផងដែរ។ បើមានសំណើមបរិយាកាសខ្ពស់ (ខ្ពស់ជាង៨០%)ក្នុងកំឡុងពេលកំពុងចេញផ្កា និង ចាប់ផ្តើមចេញផ្លែ គឺជាឥទ្ធិពលមិន ល្អដល់បរិមាណ និង គុណភាពរបស់ទិន្នផលស្វាយចន្ទី។

**ង.ខ្យល់**

ជាការល្អចំពោះស្វាយចន្ទី ល្បឿនខ្យល់គួរត្រឹមតែ ២ ទៅ ៧ ម ក្នុងមួយនាទី ឬ ២០ គ.ម ក្នុងមួយម៉ោង។

**ច.ដី**

ស្វាយចន្ទីជាប្រភេទរុក្ខជាតិមួយធន់ទ្រាំល្អ ចំពោះដីអាចដាំដំណាំស្វាយចន្ទីគឺអាចដាំលើដីគ្រប់ចំណាត់ថ្នាក់លើកលែងតែដី ដែលមានល្បាយឥដ្ឋច្រើនដែលជាដីជាំទឹក ហើយដែលល្អនោះជាដីល្បាយខ្សាច់ មិនដក់ទឹក ស្រស់ទឹកល្អ។ ចំពោះដីបាសាល់ ឬដីក្រហមឡាតារីតគឺជាប្រភេទដីដែលល្អបំផុតដែលផ្តល់ផលបានខ្ពស់ និង ផលិតផលមានគុណភាព។ ស្វាយចន្ទីអាចដាំនៅលើដីដែលមានរយៈកំពស់ ៧០០ ម ពីនីវ៉ូទឹកសមុទ្រ។

## ២.៣ ប្រភេទពូជ

-ពូជលឿង ពូជនេះនៅពេលដែលមានផ្លែពណ៌លឿង ផ្លែមានរាងមូល និង ខ្លះទៀតមានរាងមូលដូចផ្លែប៉ោម ។ ពូជនេះមានរស់ជាតិខុសគ្នាទៅតាមប្រភេទពូជផ្សេងៗ ខ្លះមានរស ជាតិផ្អែម ខ្លះជូរអែម និង ខ្លះទៀតមានរសជាតិភ្លាវ ។ ចំពោះគ្រាប់វិញភាគច្រើនមិនខុសគ្នាទេ ។ ចំពោះស្លឹកពូជលឿងនៅបរិវេណត្រួយមានពណ៌បៃតងលាយពណ៌លឿង ស្លឹកធំតែស្តើង ។ ពូជលឿងគឺផ្តល់អោយទិន្នផលច្រើន ។

-ពូជក្រហម ពូជនេះនៅពេលទុំ ផ្លែវាមានពណ៌ក្រហម មានរាងដូចពូជពណ៌លឿងដែរ ហើយមានរសជាតិផ្សេងៗពីគ្នា ។ គ្រាប់មានរាងស្រដៀងគ្នាត្រួយពណ៌ត្នោត គែមស្លឹករមូរ និង មានកំរាស់ក្រាស់ ។

-ពូជនាំចូលពីប្រទេសថៃ និង វៀតណាម ៖

-ពូជស៊ីសាកេត ៦០-១ ជាពូជដែលអោយផលខ្ពស់ ហើយអោយផលថេរ ជាពូជស្រាលខ្នាតនៃសាច់គ្រាប់ ភាគច្រើនស្ថិតនៅក្នុងលំដាប់ថ្នាក់លេខ ៣ នៃទីផ្សារពិភពលោក ។

-ពូជស៊ីសាកេត ៦០-២ ជាពូជដែលអោយផលខ្ពស់ គ្រាប់ធំ ហើយសាច់គ្រាប់ភាគច្រើនស្ថិតក្នុងលំដាប់ថ្នាក់លេខ ២-៣ នៃទីផ្សារពិភពលោក ។

-ពូជ PN1 មានប្រភពមកពីវៀតណាម មានសំបកគ្រាប់ស្តើង

-ពូជ KH1 មកពីប្រទេសថៃផ្តល់ផលខ្ពស់នឹងកំពុងដាំនៅចំការស្វាយចន្ទីស្គន់

-ពូជ PH2 មកពីប្រទេសថៃផ្តល់ផលខ្ពស់នឹងកំពុងដាំនៅចំការស្វាយចន្ទីស្គន់

## ២.៤ គំរោងប្រព័ន្ធដំណាំចំរុះ

### ២.៤.១ ចន្លោះរង និង ដើម

ដំណាំចន្លោះរងមានការទទួលយកតិចតួចបំផុត នៅពេលមិនទាន់មានប្រព័ន្ធដាំដុះដំណាំស្វាយចន្ទីក្នុងកំរិតធំ ។ ពេលដែលមានការបង្កើតប្រពន្ធ័ដាំដុះអោយមានទ្រង់ទ្រាយធំ (ដាំជាលក្ខណៈបណ្តុះកូននៅក្នុងចំការ) ដំណាំចន្លោះរងចាប់ផ្តើមទទួលយកមកអនុវត្តន៍ ។

គំលាតនៃការដាំដុះស្វាយចន្ទី គឺ:

-នៅពេលដាំឆ្នាំដំបូង ចំងាយ៨ ម ពីដើមទីមួយៗ និង ៨ ម រវាងជួរទីមួយៗ ត្រូវនឹង ២៥ ដើម ក្នុងផ្ទៃដី ៤0 ម២ (ចំពោះដីបាសាល់ ចន្លោះដើម ពិដើមមួយទៅដើមមួយ គឺ ១២ ម ឬ ១៥ ម) ។

-នៅពេលមានអាយុ ៧ ទៅ ៨ ឆ្នាំ មែករបស់វានឹងប៉ះគ្នា ត្រូវកាប់ជួររវាងដើមនឹងដើមចេញ គឺនៅសល់គំលាតពី ៨ ម x ១៦ ម ត្រូវនឹង ១១ ដើមក្នុងផ្ទៃដី ៤0 ម២ ។

-ពេលមានអាយុ ១១ ទៅ ១២ ឆ្នាំ ត្រូវកាប់ដើមរវាងជួរចេញនៅសល់ ១៦ ម x ១៦ ម ត្រូវនឹង ៥ ដើម ក្នុងផ្ទៃដី ៤0 ម២ ។

យើងអាចដាំញឹកជាងនេះ ព្រោះស្វាយចន្ទីនឹងផ្តើមអោយផលក្រោយពេលដាំដុះប្រមាណ ២-៣ ឆ្នាំ ហើយក្នុងកំឡុងពេលនោះ ការបែកមែករបស់វានៅមិនទាន់ប៉ះគ្នានៅឡើយ យើងអាចដាំគំលាតតូចជាង ៦ ម x ៦ ម គឺក្នុងករណីយើងមិនដាំដំណាំនៅចន្លោះរង ការធ្វើរបៀបនេះគឺដើម្បីកុំអោយខាតដី អាចប្រមូលទុនបានមកវិញ និង ដាំញឹកអាចកាត់បន្ថយនូវរុក្ខជាតិចង្រៃ។ បើនៅលើដីមានជីជាតិ គួរដាំចំងាយរវាងដើម និង ជួរ ៣,៥ ម x ៣,៥ ម ។ ប៉ុន្តែបើដីដែលខ្សោះជីជាតិត្រូវដាំចំងាយដើម និង ជួរ ៣ ម x ៣ ម នៅពេលដែលដើមលូតលាស់ធំឡើង ហើយមែករបស់វាចាប់ផ្តើមប៉ះគ្នា យើងចាប់ផ្តើមកាប់ដើមចោល ។

### ២.៤.២ ដំណាំចន្លោះរង ឬ ចន្លោះជួរ (ិនតរេចរៀជដិនខ)

ពពួកសណ្តែក ដូចជា សណ្តែកសៀង, សណ្តែកអង្គុយ, សណ្តែកដី, ចេក បន្លែត្រូវបានដាំនៅចន្លោះគុម្ព ។ ការដាំដុះដំណាំម្នាស់ គឺជាដំណាំដែលមានអាយុក្រោម ២ឆ្នាំ បានផ្តល់នូវលក្ខណៈសេដ្ឋកិច្ចវិញក្នុង ៤-៥ ឆ្នាំដំបូង។ ការដាំដុះដំណាំម្នាស់នៅក្នុងស្នាមភ្លោះក្នុងចន្លោះរងដែលកាត់ទីជំរាល គឺអាចធ្វើបានល្អ និង ទទួលបានការចំណេញច្រើនជាងដំណាំផ្សេងៗ ដូចជា ដំឡូងឈើ្ប ដំណាំចំណីសត្វ, រមៀត ។

ដើមស្វាវ និងអាកាស្យា ជាពពួកដើមឈើថាមពលដែលអាចដាំរវាងគ្នានឹងគ្នា ១.៥ម x ១.៥ម តាមបណ្តោយដំណាំស្វាយចន្ទី ។ យើងអាចធ្វើការដាំដុះដំណាំចំណីសត្វផងដែរ ព្រមទាំងដំណាំជីស្រស់ជាដំណាំចន្លោះរងអាចទទួលផលរហូតដល់អាយុ ៥ ឆ្នាំ ដោយគ្មានការទទួលឥទ្ធិពលពីដំណាំចំបងទេ។ បើប្រពន្ធ័ដាំជារបងមានចន្លោះរវាងជួរ (១០ម x ៥ម) គឺត្រូវបានអនុវត្តន៍ជាមួយដំណាំស្វាយចន្ទី ចន្លោះពីរជួរម្តង ប្រភេទឈើដាំនៅចន្លោះ ១-១,៥ ម ។

ប្រភេទដើមឈើត្រូវដាំចំងាយ ៣,៥ ម ពីដំណាំស្វាយចន្ទី មធ្យោបាយមួយទៀត គឺមានទំហំ ៣ ម៉ែត្រសម្រាប់ដាំដើមឈើ ២ ជួរ ។

ចំពោះដំណាំរមៀត ក៏អាចជាដំណាំចន្លោះរងបានដែរ ក្នុងកំឡុងពេល ៥ ឆ្នាំដំបូង។

ស្វាយ ស្វា ខ្នុរ និង ដូង ជាដំណាំដែលមានអាយុច្រើនឆ្នាំដូចស្វាយចន្ទី អាចធ្វើជាប្រព័ន្ធដំណាំចំរុះបាន។ ម្រេច និង វាល់នីឡាក៏អាចដាំនៅចន្លោះដើមស្វាយចន្ទីផងដែរ។




**ដំណាំចន្លោះរង ( ម្រេច ម្នាស់ ...)**

### ២.៤.៣ ការដាំដំណាំគំរបដី ( *Cover Cropping* )

ដោយការដាំដំណាំគំរបដី មានអត្ថប្រយោជន៍ជួយដល់ការទប់ទល់នឹងការហូរច្រោះ រក្សាសំណើមដី និង ធ្វើអោយដីមានជីជាតិថែមទៀតផង ហើយជួយក្នុងការកាត់បន្ថយការរំហួតពេលក្តៅខ្លាំងដោយដាំដំណាំគំរបដីមានដូចជា ពពួកសណ្តែកដី សណ្តែកអង្គុយ ស្នោសេស្បានីញ៉ារូស្ត្រាតា (ស្រេសេបានិា Rostratta) ។

## ២.៥ បច្ចេកទេសដាំដុះដំណាំស្វាយចន្ទី

### ២.៥.១ ការរៀបចំចំការដាំស្វាយចន្ទី

ចំពោះដំណាំស្វាយចន្ទីដែលជាដំណាំឧស្សាហកម្មដែលមានរយៈពេលយូរ ហើយការដាំលើផ្ទៃដីធំទូលាយ ដូច្នេះទាមទារនូវការរៀបចំដីតាមលក្ខណៈបច្ចេកទេសអោយបានម៉ត់ចត់ ទើបគេអាចទទួលបានលទ្ធផលច្រើន។

វិធីសាស្ត្រក្នុងការរៀបចំដីរួមមាន:

-ការកាប់ឆ្ការព្រៃ

-ការសាងសង់ផ្លូវ

-ការសាងសង់ប្រឡាយទឹក

-ការដាំដំណាំគំរបដី

**ការកាប់ឆ្ការព្រៃសំអាតដី**

ចំពោះបញ្ហាកំលាំងពលកម្មគេអាចប្រើប្រាស់ កម្មករ និង គ្រឿងយន្ត ដើម្បីសំអាត និង រៀបចំដី។ ចំពោះដើមឈើងាប់ គេត្រូវគរវាជាគំនររួចធ្វើការដុតដោយប្រុងប្រយ័ត្ន។ ចំពោះគល់ឈើត្រូវអោយកម្មករ

កាប់ ឬ គាស់ ឬដោយម៉ាស៊ីន។ ម្យ៉ាងទៀតឫស និង គល់ឈើត្រូវយកវាអោយអស់ពីដីរួចគរជាគំនរ ហាលអោយស្ងួតរួចដុតវាចោល ។ ចំពោះករណីដុតព្រៃជាទ្រង់ទ្រាយធំ ជាធម្មតាប្រព្រឹត្តទៅ ៦-៨ សប្តាហ៏ក្រោយ ពេលកាប់ឆ្ការ ។

**ការសង់ផ្លូវ**

បន្ទាប់ពីដុតព្រៃរួច ការសង់ផ្លូវត្រូវគិតគូរជាបន្ទាន់ ដោយប្រយ័ត្ន និង ដោយធ្វើការកំណត់អោយបានច្បាស់ ។ ផ្លូវត្រូវមានទទឹង ៥-៦ ម ងាយស្រួលដល់ការដឹកផលិតផល។

**ការសង់ប្រឡាយ**

លក្ខណៈនៃប្រឡាយៈ ផ្នែកបាតខាងលើពី ២-៦ ម ផ្នែកបាតខាងក្រោមពី ១,២-១,៨ ម ជំរៅ ១,៨-២,៧ ម។ ដោយចន្លោះប្រឡាយមួយទៅប្រឡាយមួយមិនលើសពី ១០០ ម ហើយកូនប្រឡាយទាំងនោះត្រូវជីកកែង និង ប្រឡាយមេ ដែលមានទំហំប្រែប្រួលពី ៖

ផ្នែកបាតលើពី ១,៨-២,៧ ម

ផ្លែកបាតក្រោមពី ០,៦-០,៩ ម

ជំរៅមាន ១,២-១,៨ ម ដើម្បីងាយស្រួលដល់ការដំណើរការគ្រឿងយន្ត កូនប្រឡាយដែលជីកចូលចំការត្រូវតែមានលក្ខណៈស្របគ្នាហើយមានទិសដៅតែមួយ ។

**២.៥.២ ការរៀបចំដី**

ការរៀបចំដីត្រូវធ្វើអោយបានរួចស្រេចនៅក្នុងខែមេសា ។

**២.៥.៣ ការជីករណ្តៅ**

គួរតែជីករណ្តៅដែលមានទំហំ ១ ម x ១ ម x ១ ម ចំពោះដីល្បាយខ្សាច់។ ចន្លោះដើម ៨ ម x ៨ ម ជាការល្អ។ ក្នុងករណីដីជំរាលធ្វើចង្អូរកាត់ដីជំរាល ពី ១០-១៥ ម ។ ប្រសិនបើដីបន្ទាប់ពីស្រទាប់លើរឹងមានរាងដូចខ្ទះ ដូចនេះទំហំរណ្តៅត្រូវបង្កើតឡើងអោយធំ ១.២ ម x ១,២ ម x ១,២ ម ។ ស្វាយចន្ទីដាំនៅចន្លោះជួរ ៨ ម x ៨ ម ចន្លោះជួរនេះក៏ផ្តល់លទ្ធភាពក្នុងការលូតលាស់ដែរ។ រណ្តៅត្រូវជីក ១៥-២០ ថ្ងៃ ដំបូងការដាំដុះ ហើយដាក់អោយ ត្រូវថ្ងៃដើម្បីកំចាត់កត្តាចង្រៃនៅក្នុងដី។ បន្ទាប់មករណ្តៅត្រូវបំពេញកំពស់ ៣,៤ ដោយលាយចំរុះគ្នាដូចជា ដីស្រទាប់ លើ ជីកំប៉ុស្តិ៍ ១១ គ.ក្រ និង ថ្មផូស្វាតធម្មជាតិ ២០០ ក្រាម។ ប្រសិនបើដីរាបស្មើ ការត្រៀមដីស្មើរតែមិនចាំបាច់ធ្វើអ្វី ឡើយ គ្រាន់តែសំអាតស្មៅចង្រៃចេញ ឬ ក៏ធ្វើការភ្ជួរពីរដងហើយដាក់ដាំស្វាយចន្ទីអោយមានជួរតាមរបៀបរៀប រយ។ ប៉ុន្តែដីដែលមានព្រៃ ត្រូវគាស់រំលើងយកគល់ចេញជាមុនសិន ដើម្បីងាយស្រួលក្នុងការថែរក្សា ប្រសិនបើជាដីទួលគួរពង្រាបទៅតាមជំរាលដី។ ម្យ៉ាងទៀតបើដីនោះចោតខ្លាំង ឬ ដីភ្នំ ការដាំដុះធ្វើឡើងជាកាំជណ្តើរដើម្បីការពារការហូរច្រោះ និង ការបាក់ដី។ ការត្រៀមដីគួរធ្វើអោយស្រេចនៅក្នុងរដូវក្តៅ ដែលអាចជីករណ្តៅនឹងដាំបាននៅក្នុងរដូវភ្លៀង។

### ២.៥.៤ ការដាំដុះ

រុក្ខជាតិដែលអនុវត្តន៍វិធីសាស្រ្តពង្រីកសរីរាង្គលូតលាស់ គឺទទួលទិន្នផលខ្ពស់ជាទីគាប់ចិត្ត។ ជួសអោយការប្រើប្រាស់ពូជតែមួយ ទៅមុខទៀតគេចូលចិត្តដោយប្រើ ពូជ ២-៤ ដើម្បីជៀសផុតពីបញ្ហាកត្តាចង្រៃ និង ពូជដែលឆាប់ចេញផ្កានៅដើមរដូវ។

ការដាំបញ្ចូលគ្នារវាងពូជកណ្តាល និង ពូជធ្ងន់ គឺជាការល្អណាស់ ។ រុក្ខជាតិមានសុខភាពល្អត្រូវដាំដោយប្រុងប្រយត្ន័ បន្ទាប់ពីយកថង់ប្លាស្ទិកចេញដោយមិនអោយប៉ះពាល់ដល់ឫស។ ដីដែលស្ថិតនៅកណ្តាលរណ្តៅកាយចេញដើម្បីដាក់កូនរុក្ខជាតិ។ បន្ទាប់ពីដីបង្ហាប់ល្មមហើយ ដាក់រុក្ខជាតិចូលទៅក្នុងរណ្តៅដែលបានកាយដីចេញនោះ។

ក្នុងករណីបំបៅការថែទាំគួរតែយកចិត្តទុកដាក់មុខតំណបំបៅ គឺតិចបំផុតលើ ៥ ស.ម ពីមាត់រណ្តៅសំអាតនិ៏ងជួយអោយរកឃើញហើយបន្ទាប់មកកាត់ពន្លកដែលនៅគល់ឬសតែនៅក្រោមមុខតំណបំបៅ។ ផ្នែកដែលនៅសល់នៃរណ្តៅគួរបំពេញបន្តិចម្តង១ ចាប់ពីបាតរណ្តៅ រយៈពេល ២ ឆ្នាំ។

#### ការត្រៀមគ្រាប់ពូជសម្រាប់ដាំ

-ទម្ងន់គ្រាប់មិនស្រាលជាង ៥ ក្រាមក្នុង ១ គ្រាប់

-នៅពេលត្រាំទឹកគ្រាប់វាលិចទៅក្នុងទឹក

#### ពេលវេលាដាំដុះ

ទោះបីជាស្វាយចន្ទីវាធន់ និង ភាពរាំងស្ងួតក៏ដោយ ក៏នៅវគ្គដំបូងនៃការលូតលាស់វាត្រូវការទឹកដើម្បីការលូតលាស់ធំរឹងប៉ឹងដែរ ដូច្នេះត្រូវកំណត់រដូវដាំដុះអោយបានល្អ ។ រដូវកាលដែលសមរម្យសម្រាប់ការដាំដុះគឺដើមខែ មិថុនា ដល់ ខែកក្កដា វានឹងទទួលបានទឹកភ្លៀងរយៈពេល៣ខែ ម្យ៉ាងវិញទៀតគេអាចដាំវាបាននៅក្នុងខែសីហាដោយពុំសូវធ្វើ ការស្រោចស្រពច្រើន ។

#### ការបណ្តុះកូននៅក្នុងថ្នាលបណ្តុះ

យកគ្រាប់ទៅដាក់កប់ក្នុងថ្នាលដែលយើងក្រាលដីខ្សាច់កំរាស់ ១៥ ស.ម ។ ការដាក់គ្រាប់ត្រូវយកផ្នែកខាងផតចុះទៅក្រោម ហើយងើយខាងក្បាលគ្រាប់ឡើងបន្តិច រួចរោយខ្សាច់ពីលើគ្រាប់អោយបានកំរាស់ ២,៥០ ស.ម និងស្រោចទឹក ២ ដង ក្នុងមួយថ្ងៃ នៅពេលព្រឹក និង ពេលល្ងាចរយៈពេល ៦ ថ្ងៃ ក្នុងករណីមានភ្លៀងធ្លាក់មិនចាំបាច់ស្រោចទឹកទេ ។

#### ការបណ្តុះកូននៅក្នុងថង់ប្លាស្ទិក

ត្រៀមគ្រាប់ពូជដែលបានជ្រើសរើសរួចហើយ ទៅបណ្តុះក្នុងថង់ប្លាស្ទិកត្រូវធ្វើការត្រាំគ្រាប់រយៈពេល ២៤ ម៉ោង ទៅ ៤៨ ម៉ោង មុនពេលយកទៅបណ្តុះ។ ថង់ប្លាស្ទិកគួរប្រើថង់ពណ៌ខ្មៅដែលមានទំហំ ១២,៧ ស.ម x ២០,៣ ស.ម ដោយប្រើថង់ជ្រៅកាន់តែល្អ បើថង់រាក់វាធ្វើអោយការចាក់ឫសរបស់វាទាល់ដោយធ្វើការចោះរន្ធចំហៀងអោយបាន ពី

៤-៨ រន្ធ ដើម្បីបញ្ចេញទឹកពីក្នុងថង់ ។ ការបណ្តុះធ្វើឡើងដោយការផ្សំដីជាមួយនឹងផេះអង្កាម ជីទ្រាប់បាត ឬ កំប៉ុស្តិ៍នៅក្នុងអត្រា ៣៖១០:១ ដោយច្របល់បញ្ចូលគ្នាអោយសព្វ ហើយច្រកចូលថង់ដែលបានធ្វើការត្រៀមទុក អោយសល់ពីមាត់ថង់ប្រហែល ១-២ ស.ម ។



បេះផ្លែដែលល្អគ្មានការបំផ្លាញពីកត្តាចង្រៃ



ប្រឡេះគ្រាប់ពីផ្លែ



យកដីស្រទាប់លើឬដីមមោក



យកដីដែលល្អ



យកដីច្រកចូលក្នុងថង់ប្លាស្ទិក



បង្ហាប់វាឱ្យហាប់ល្មម



ថង់ប្លាស្ទិកដែលត្រៀមទុក



យកម្រាមដៃកាយប្រហោងល្មមដាក់គ្រាប់



ដាក់គ្រាប់ស្វាយចន្ទីចូលក្នុងប្រហោង



កាយដីលប់ពីលើគ្រាប់



ស្រោចទឹកកុំឱ្យខ្ចាយដី



ទុកឱ្យដុះលូតលាស់

**រូបភាពការបណ្តុះកូននៅក្នុងថង់**

**វិធីដាំដោយគ្រាប់**

វិធីនេះសមស្របចំពោះការដាំនៅលើផ្ទៃ ដីធំទូលាយ ករណីនេះមិនធ្វើអោយកូនរអាក់រអួលក្នុងការលូតលាស់ ហើយ ម្យ៉ាងទៀតមិនសូវចំណាយពេលកម្មក្នុងការដាំដុះ ប៉ុន្តែត្រូវរង់ចាំថែរក្សានិងការដាំជួសចំពោះរណ្តៅណាដែលមិនដុះ ឬកូនមិនរឹងមាំ ។ ដាក់គ្រាប់ ២-៣ ក្នុង១រណ្តៅដាំតែម្តង ការកប់គ្រាប់មិនត្រូវអោយជ្រៅលើសពី ៦ ស.មទេព្រោះបើជ្រៅវាមិនដុះ ឬ បាត់បង់ចោលទទេ ។ បន្ទាប់ពីកប់គ្រាប់រួចរាល់ហើយត្រូវធ្វើការស្រោចទឹកអោយបានល្អ ហើយធ្វើការបោចស្មៅ និង យកចំបើងមកគ្រប ដើម្បីការពារសំណើមមិនអោយមានការស្រោចទឹកជាញឹកញាប់។

នៅពេលស្លឹកដុះចេញនូវស្លឹកពិតប្រាកដ ឬ រឹងប៉ឹងហើយ ត្រូវធ្វើការដកដើមអន់ចេញអោយនៅសល់តែមួយដើម។ ការជីករណ្តៅគួរមានទំហំ ៥០ ស.ម x ៥០ ស.ម និង ជំរៅ ៥០ ស.ម។

**ការស្រោចស្រព**

ប្រសិនបើខ្វះទឹក ធ្វើអោយការលូតលាស់វារអាក់រអួលយឺតជាងធម្មតា ។ ដោយនៅឆ្នាំដំបូងគួរធ្វើការស្រោចទឹកនៅពេលគ្មានភ្លៀង ដើម្បីជួយបង្កើតសន្ទុះនៃការលូតលាស់អោយបានធំរហ័ស និង ទទួលផលឆាប់ជាងប្រក្រតី។ បើនៅរដូវប្រាំងគួរយកស្មៅ និង ចំបើងទៅគ្របត្រង់គល់ដើម្បីរក្សាសំណើមអោយបានយូរ ។

នៅឆ្នាំបន្ទាប់ទៀត ត្រូវធ្វើការស្រោចទឹកនៅរដូវក្តៅដែលមានរយៈពេលយូរៗតែប៉ុណោះ ការស្រោចទឹកធ្វើអោយដើមលូតលាស់បានល្អ ហើយប្រការសំខាន់ គឺរក្សាសំណើមនៅក្នុងចន្លោះរងដាំដុះ គឺត្រូវភ្ជួរតាមចន្លោះមុនពេលអស់ទឹកភ្លៀង ។ស្វាយចន្ទីអាចដុះលូតលាស់នៅតំបន់ដែមមានលក្ខខណ្ឌទឹកភ្លៀងតិចតួច ។ទោះបីវាបន្ថែមប្រពន្ធ័ស្រោចស្រពកំឡុងពេលរដូវក្តៅក៏ដោយ ជាពិសេសខែមករាដល់ខែមិនាត្រូវផ្តល់ទឹករយៈពេលពីរអាទិត្យម្តងៗ **២០០ ល,ដ។** នេះជាលទ្ធផលស្រាវជ្រាវ មួយទទួល បានពីមជ្ឈមណ្ឌលស្រាវជ្រាវដំណាំស្វាយចន្ទីរបស់ឥណ្ឌា ហើយផ្តល់ផលទ្វេរដងបើបរិមាណនៃការផ្គត់ផ្គង់ទឹកដែលល្អគឺប្រើប្រាស់ការសំរក់ទឹកក្នុងអត្រា៦០-៨០លីត្រ ក្នុងមួយដើម ក្នុងមួយថ្ងៃ នៅរយៈពេល ២ថ្ងៃបន្ទាប់ពីការចេញផ្កាដំបូងរហូតដល់ចេញផ្លែ និង ការវិវត្តន៍។

ស្វាយចន្ទីមិនអាចប្រឈមមុខនឹងការលិចទឹកបានទេ នៅតំបន់ដែលមានភ្លៀងធ្លាក់ច្រើន គួរតែរៀបចំប្រពន្ធ័បង្ហូរ ទឹកចេញ។

**ការថែទាំទូទៅលើដីចំការចាស់**

កំឡុង ២-៣ ឆ្នាំម្តង សួនចាស់នៃដំណាំស្វាយចន្ទី មានម្លប់ដោយខ្លួនឯងហើយត្រូវធ្វើការតាក់តែងមែកដើម្បីសំរួលដល់ខ្យល់ និង ពន្លឺចាំងចូលគ្រប់គ្រាន់ដើម្បីសំងួតដីល្អ ។ ការតាក់តែងមែកត្រូវធ្វើឡើងនៅក្នុងខែសីហា និងការកាត់ ចុងក្រោយ ត្រូវលាប Bordeaux 10% ។

**២.៥.៥ ការបោះបង្គោលជាប់កូនឈើ និងគំរបដី**

បន្ទាប់ពីការដាំកូនបំបៅយកបង្គោលទៅចងភ្ជាប់ ។ ធ្វើដូចនេះដើម្បីបង្កាការខូចខាតដល់កូនបំបៅ ដោយសារខ្យល់ ចំពោះដីដែលនៅជុំវិញរុក្ខជាតិត្រូវគ្រប និងស្លឹកស្ងួត ឬ ស្លឹកស្រស់សម្រាប់ការពារសំណើមកុំអោយបាត់បង់ ។



**គ្របគំរបស្លឹករុក្ខជាតិ និង ឈើទប់ដើម**

**២.៥.៦ ការកាត់មែកស្វាយចន្ទី ( ចំពោះដើមដាំដោយគ្រាប់ តត្រួយ និង សាក)**

ដើមដាំដោយគ្រាប់ និង ដើមបំបៅដោយត្រួយក្រោយពេលដាំបានអាយុ ១-៣ ឆ្នាំ ត្រូវពិនិត្យលើការបោះមែក(គូរោន)ក្នុងដើមនីមួយៗ បើសង្កេតឃើញថាដើមណាមានគូរោនមិនល្អគួរកាត់មែកខ្លះ ចោល រួមទាំងមែកងាប់ និង មែកដែលមានជំងឺ ។ ការកាត់នេះអោយនៅសល់ដងដើមតែមួយដើម្បីរក្សាគូរោនអោយបានសមរម្យ និង ងាយស្រួលថែរក្សាការកំចាត់សត្រូវស្វាយចន្ទី។ ពេលវាមានអាយុ ១-៣ឆ្នាំ គួរកាត់មែកក្រោមអោយផុតពីដីកំពស់៥០ស.ម។ សម្រាប់ ដើមអោយផលហើយនៅពេលប្រមូលផល រួចក៏គួរកាត់មែកចេញខ្លះដោយកាត់មែកនៅផ្នែកខាងក្នុងគូរោន។ ចុងរដូវភ្លៀង ឬមុនរដូវចេញផ្កាប្រមាណ ៣ខែត្រូវកាត់មែកខ្មែងចេញនៅពេលកាត់ រួចហើយ និងមានរាងគូរោនសមរម្យហើយ ជៀសវាងពីជំងឺ និង សត្វល្អិតដោយងាយរក្សា និង ងាយប្រមូលផលហើយ ទទួលទិន្នផលបានច្រើនជាងមិនកាត់មែក ។

**២.៦ ការអភិរក្ស ដី និងទឹក**

នៅក្នុងករណីដីជំរាលចាំបាច់ជីករណ្តៅបណ្តោយ ២-២,៥ ម ទទឹង ០,៣ ម ជំរៅ ០,៤៥ ម ចំងាយ ២ ម ពីដើមនៅផ្នែកខាងលើទីជំរាល។ ករណីស្មើល្អត្រូវជីករណ្តៅរាងជារង្វង់ ឬ ជាការ៉េ ចំងាយពីដើម ២ ម ជំរៅ ០,៣ ម និងមាត់រណ្តៅ ទំហំ ០,៣ ម គួរតែជីកដីជុំវិញដើម។ បន្ទាប់ពីការងារលើកដី ជុំវិញដើមគួរតែប្រើប្រាស់គំរបសារធាតុ

សរីរាង្គទប់ទល់នឹងការហូរច្រោះនៅរដូវវស្សា ហើយម្យ៉ាងទៀត ជៀសវាងការប៉ះពន្លឺដោយផ្ទាល់ នេះជាមធ្យោបាយសម្រាប់ការពារសំណើមដីនៅរដូវក្តៅ។



ការជីករណ្តៅនៅជុំវិញគល់ដើម្បីកាត់បន្ថយការហូរច្រោះដីជាតិ



ការជំរះសំអាតពីក្រោមគល់ដើមចន្ទី



ការពង្រាយសារធាតុសរីរាង្គជុំវិញគល់

## ២.៧ ការការពារកន្លាចជ្រៃ

កន្លាចជ្រៃគឺករណីចំបងបំផុតដែលមានការប៉ះពាល់ខ្លាំងលើទិន្នផល និង គុណភាពរបស់ផលិតផលដំណាំស្វាយចន្ទី។ ជាទូទៅផលិតផលស្វាយចន្ទីមិនប្រើប្រាស់ថ្នាំគីមី និង ជីគីមី មានតំលៃលើសផលិតផលដែលប្រើប្រាស់សារធាតុគីមី។ ទោះបីជាយ៉ាងណាក៏ដោយនៅពេលដែលនិយាយពីការប្រើសារធាតុគីមីដើម្បីការពារ និងព្យាបាល អ្នកកសិកម្មជំនាញនៅតាមតំបន់គួរពន្យល់ទៅសិក្ខាកាម ឬកសិករ ថានេះជាជម្រើសចុងក្រោយដែលយើងយកមកអនុវត្តន៍។ ពេលដែលប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតខុស នោះនាំឱ្យពួកគេមានបញ្ហាផ្នែកសុខភាព នៅពេលកំពុងតែអនុវត្តន៍ និង បញ្ហាដល់បរិស្ថានបើសិនជាជាតិគីមីមានការប៉ះពាល់ទៅលើសត្វមានប្រយោជន៍ ឬ ក៏ហូរចូលទៅក្នុងបឹងបួរ ស្ទឹង។ ប៉ុន្តែការពិចារណាដ៏សំខាន់គឺទៅលើការចំណាយរបស់ពួកគេ។ សម្រាប់អ្នកដែលមានទំហំផ្ទៃដីតូចគ្មានការប្រើប្រាស់ ជាតិគីមី និង ចំណេញលើការបំផ្លាញសត្វល្អិតខ្លះឱ្យវិនាស ជាងការប្រើប្រាស់សារធាតុគីមីដែលមានតំលៃថ្លៃ។

អ្នកកសិកម្មជំនាញនៅតាមតំបន់គួរតែសំគាល់ពីគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កំពុងជំរុញនូវផលិតផលផ្លែកចំនីអាហារនៅក្នុងប្រទេសកម្ពុជា គ្មានជាតិគីមី។

ខាងក្រោមនេះគឺជាកត្តាចង្រៃមួយចំនួន ដែលមានវត្តមានតាមតំបន់ភាគច្រើននៅកម្ពុជាហើយផ្តល់ផលប៉ះពាល់ទៅលើដំណាំស្វាយចន្ទី៖

**២.៧.១ ជំងឺ**

**ជំងឺរលួយគល់ និង ឫស**

**ក លក្ខណៈបំផ្លាញ**

កើតឡើងនៅថ្នាលបណ្តុះកូន កូនក្នុងថង់ ឬ ថ្នាលបណ្តុះកូន។ លក្ខណៈនៃការបំផ្លាញគឺវាបំផ្លាញនៅបរិវេណគល់ និង ឫស ដំបូងឃើញឆ្នូតតាមគល់ និង បន្ទាប់មកទៅជាពណ៌ត្នោតឬពណ៌ខ្មៅ បន្ទាប់ត្រួយ និង ស្លឹកចាប់ផ្តើមស្រពោន និង ងាប់នៅពេលបន្ទាប់។ នៅបរិវេណគល់អាចឃើញសរសៃពណ៌ស និង នៅពេលដកដើមចេញឃើញរលួយឫសនឹងមានពណ៌ខ្មៅ។ ជំងឺនេះអាចកើតនៅលើស្លឹក ដែលមានលក្ខណៈដូចរលាកទឹកក្តៅហើយទ្រនុងស្លឹកដែលនៅជាប់ស្នាមរលាកនោះមានពណ៌ខ្មៅ ជំងឺនេះរាតត្បាតនៅរដូវភ្លៀង ។

**ខ វិធានការកំចាត់ និង ការពារ**

ការការពារធ្វើឡើងដោយរៀបចំដីអោយរាបស្មើ ជ្រាបទឹកបានល្អ ហើយការដាក់គ្រាប់បណ្តុះមិនអោយជ្រៅពេកទេ ការដាក់ជីអាសូតត្រូវបន្ថយខ្លះ ឬ ហាលដីអោយបានល្អ ឬ ធ្វើ Fumigation (បង្ហុយសារធាតុថ្នាំគីមីដើម្បីសំលាប់ពពួកមេរោគបង្កជំងឺ) ដីជាមួយមេទីលប្រូម៉ាយ ក្នុងអត្រា ០,៥ គ.ក្រ ក្នុងដី ១ ម៣ ។

**ជំងឺរលួយផ្លែ**

**ក លក្ខណៈបំផ្លាញ**

កើតឡើងពីផ្សិតមួយប្រភេទដែលរាតត្បាតនៅពេលចេញផ្លែ នៅក្នុងខែមិនា ដល់ ខែកក្កដានៅពេលដែលផ្លែចាប់ផ្តើមទុំ។ ផ្លែ វាមានលក្ខណៈពណ៌ខ្មៅហើយរីកធំពេញផ្លែទាំងមូល ជួនកាលគេសង្កេតឃើញមានផ្សិត ឬ បាក់តេរីប្រភេទផ្សេងៗចូលរួមបំផ្លាញ ដែលធ្វើអោយរលួយមានសណ្ឋានជាពពុះជួនកាលវាក៏កើតនៅលើផ្លែខ្ចីផងដែរ។ តែជួនកាលវាបំផ្លាញទៅលើគ្រាប់ និង កញ្ចុំផ្កាដែលធ្វើអោយរលួយមានពណ៌ខ្មៅ បន្ទាប់មកក៏ធ្វើអោយផ្ការុះរោយ។

**ខ វិធានការកំចាត់ និង ការពារ**

ការកំចាត់ដោយប្រើថ្នាំ គូប្រាវីត (ជុផរាវិត)ក្នុងអត្រា ៥០-៦០ ក្រាមក្នុងទឹក ២០ លីត្រ។

ថ្នាំគូប្រាវីត(ជុផរាវិត)ជាថ្នាំសំលាប់ពពួកផ្សិតដែលបង្កភាពចង្រៃលើដំណាំ។

**ជំងឺចំណុចនៅលើស្លឹក ឬ ខ្លោចស្លឹក**( Brown Leaf Spot Disease)9**ភេសេតាឡៅទិា** *sp.)*

**ក លក្ខណៈបំផ្លាញ**

វាកើតឡើងដោយសារផ្សិតច្រើនប្រភេទ ដែលសង្កេតឃើញនៅលើដើមស្វាយចន្ទីមានអាយុមិន លើស ២ឆ្នាំ។ ភ្នាក់ងារបង្កគឺផ្សិតឈ្មោះ **ប៉េស្តាឡូទីយ៉ា អេសប៉េ** (*Pestalotia sp.*) ធ្វើអោយស្លឹកកើតមានចំណុចពណ៌ប្រផេះហើយព័ទ្ធដោយពណ៌ត្នោតក្រហមដែលមានទំហំ ០,២-២ ស.ម ហើយតែងកើតនៅលើស្លឹកចាស់។ ជាពិសេស

វត្តមានរបស់វាច្រើនកើតឡើងចាប់ពី ខែកញ្ញា ដល់ ធ្នូ។ យើងអាចប្រើល្បាយ ប័រដូ(ញៀរដេ១ុខ) លាយហើយ កំហាប់ ១%. ខបផ័រអុក ស៊ុក្លរីដ ០,៣០% ឬ បែនឡែត ០,៣០%។

ផ្សិតមួយប្រភេទទៀតឈ្មោះ **កូឡិចទ្រីជុម អេសប៉េ** កើតនៅលើស្លឹកខ្ចី និង ផ្សិតឈ្មោះ **សេកូស្ពោរ៉ា អេសប៉េ** ធ្វើអោយស្លឹកមានចំណុចជ្រុង១ពណ៌ត្នោតមានទំហំ ០,១-០,៤ ស.ម បើសិនមានការរាតត្បាតខ្លាំងធ្វើអោយស្លឹក និង មែកស្ងួតហើយបែក ។

**ខ វិធានការកំចាត់ និង ការពារ**

-ស្លឹកដែលជ្រុះ ត្រូវប្រមូលហើយដុតចោលនៅខាងក្រៅ ចំការ ។

-ផ្តល់ជី នៅជុំវិញដើមនៅដើម រដូវក្តៅ ។

-ការពារនូវសំណើមចំការ ទាំងរុក្ខជាតិដែលត្រូវការពារ និង ដំណាំដែលដុះចេញដោយឯកឯង។

-ការកំចាត់ត្រូវបាញ់ថ្នាំដែលមានសារធាតុទង់ដែងជាមួយនឹងម្នាងសិលា បាញ់លើស្លឹកក្រោយពេលរដូវភ្លៀង ឬ ប្រើ គូប្រាវីត(ថ្នាំសំលាប់ផ្សិត)អត្រា ៥០-៦០ ក្រាម លាយទឹក ២០ លីត្រ បាញ់ម្តងម្កាល ។

 

**រោគសញ្ញាជំងឺអុជស្លឹកលើស្លឹកស្វាយចន្ទី**

**ជំងឺក្រៀមកញ្ចុំផ្កា** ( Flower Cluster Faded Disease)

**ក លក្ខណៈបំផ្លាញ**

កើតឡើងដោយសារផ្សិតមួយប្រភេទ ដែលធ្វើអោយកញ្ចុំផ្កាស្ងួតមានពណ៌ត្នោតចាស់ផ្កានឹងរុះរោយ បើសិនកាន់ផ្លែក៏ត្រូវជ្រុះមុនកំណត់ដែរ។ ផ្សិតប្រភេទនេះផ្តើមបំផ្លាញទៅលើទងកញ្ចុំផ្កាអាការៈនេះកើតឡើងក្រោយពេលដែលមានការបំផ្លាញដោយសារមមាចភ្លើងនឹងជាភ្នាក់ងារចំលងផ្សិតបន្ថែមទៀតផង។

**ខ វិធានការកំចាត់ និង ការពារ**

ការការពារត្រូវបាញ់ថ្នាំការពារពពួកមមាចដែលជាប្រភេទចំលងតែបើឃើញមានការបំផ្លាញរួចទៅហើយត្រូវប្រើថ្នាំបេនឡេត ៥០ ភាគរយក្នុងអត្រា ៥-១២ ក្រាម ជាមួយទឹក ២០ លីត្រ ។



**ជំងឺក្រៀមកញ្ចុំផ្កា**

**២.៧.២ សត្វល្អិតចង្រៃ**

**ដង្កូវចោះដើម** Cashew Stem and Root Borer (CSRB) (*Plocaederus obesus*)

**ក លក្ខណៈបំផ្លាញ**

ដើមស្វាយចន្ទីចាស់ទទួលរងនូវការបំផ្លាញពួកដង្កូវចោះដើមច្រើន ។ មេវាពងដាក់នៅក្នុងសំបកឈើដែលប្រេះនៃដើម ឬ នៅលើឬស ។ វាចោះស៊ីសាច់ឈើខ្ចីនៅក្រោមសំបក ហើយនៅពេលវាធំអាចចោះស៊ីដើមមែក និង ធ្វើអោយស្លឹកមានពណ៌លឿងហើយជ្រុះ និង ធ្វើអោយមែកស្ងួតហើយងាប់ បើសិនមានការចោះបំផ្លាញខ្លាំង ធ្វើអោយស្វាយចន្ទីងាប់បាន។ រន្ធ និងកំទេចឈើព្រមទាំងជ័រត្រូវបានយើងឃើញយ៉ាងច្បាស់នៅលើដើមដែលជាកន្លែងដែលត្រូវបានបំផ្លាញដោយដង្កូវ ។

បើសិនបានឃើញដូច្នេះត្រូវធ្វើការកាប់មែកដែលបំផ្លាញចោល ហើយបំផ្លាញដង្កូវចោលដោយដុតមែកនោះ ដើម្បីមិនអោយរីករាលដាលតទៅទៀត បន្ទាប់ពីនេះបើមានមេរបស់វាមកពងដាក់នៅបរិវេណ ដើម គល់ និង ឫស។

**២ វិធានការកំចាត់ និង ការពារ**

យកលួសទន់ចាក់ចូលទៅក្នុងរន្ធដឹកឈើ ត្រូវរុកចូលអោយជ្រៅរហូតដល់លឺសំលេង ឬ ទឹកសៗ រាងពពុះហៀរចេញបង្ហាញថាបានកំចាត់កូនដង្កូវ ឬ ដឹកឈើនៅក្នុងរន្ធនោះហើយ។ ផ្ទៃកសំបកដែលយើងឈូសលាង និង ទឹកល្បាយ ប័រដូ ១០ ភាគរយ។ ហើយយកប្រេងម៉ាស៊ីនដែលប្រើហើយមកលាប លើដើមពីដីឡើងមកលើប្រវែង១ ម គេប្រើប្រាស់ក្នុងខែកញ្ញា វិច្ឆិកា និង មករា ការពារការញាស់ពងប្រេងស្តៅក៏អាចធ្វើការលាងសំអាត ដើមផងដែរ។ គេធ្លាប់រកឃើញដើមដែលមានបរិវេណសំបុកដែលមានការបំផ្លាញលើស ៥០ ភាគរយ ឬមានពណ៌លឿង លើស្រទាប់លើសរីរាង្គលូតលាស់យ៉ាងក្រាស់ហើយកត្តាចង្រៃនៅតែកើតឡើង និង បន្តចំលងមេរោគនឹងសំដែងចេញទៅដើម ផ្សេងៗនៅរដូវក្រោយបន្តទៀត។ ដូច្នេះការធ្វើអនាម័យត្រូវដកដើម ឈើណាដែលហួសពេលព្យាបាល និង កំចាត់ចោលភ្លាមៗស្របពេលដឹងការរាលដាលលើដើមផ្សេងៗជាច្រើនទៀតត្រូវ កំចាត់ចេញដើម្បីទប់ទល់នឹងការកើតឡើងជាថ្មីនៃពពួកចំលងមេរោគ។ ដូចជាមានកើតឡើងនូវហេតុការណ៍បំផ្លាញ ក្នុងកំឡុងពេលកំពុងប្រមូលផលគ្រាប់ (កុម្ភៈ ដល់ ឧសភា) ដើមឈើភាគច្រើនអាចធ្វើការកត់ចំណាំ និង រកវិធានការព្យាបាលភ្លាមដូចនេះពពួកដង្កូវមិនអាចធ្វើអោយមានស្នាមបំផ្លាញច្រើនទេ។



**ដង្កូវស៊ីរូងដើម និង ឫស(លូតលាស់)**



**មេចំណាស់ពេញវ័យ**



**រោគសញ្ញាបំផ្លាញធ្ងន់ធ្ងរ**

**មូសតែ** Tea Mosquito Bug (TMB) (*Helopeltis antonii*)

**ក លក្ខណៈបំផ្លាញ**

មូសតែអាចកាត់បន្ថយទិន្នផល ៣០-៤០ ភាគរយ ដោយបំផ្លាញពីរផ្នែកខ្ចី កញ្ចុំផ្កា និង ផ្លែខ្ចីធ្វើការចុចជញ្ជក់ពីរផ្នែកខ្ចី និងគ្រាប់ខ្ចី និងផ្លែ លទ្ធផលបង្កើតជាសំលាកខ្មៅ។ សំលាកទាំងអស់នេះមាននៅលើពន្លក និង កញ្ចុំផ្កា

ដោយសារជំងឺរលួយត្រួយ ឬ ជំងឺនៅផ្កា។ រុក្ខជាតិអាចគេចចេញពីការវាយប្រហាររបស់មូសតែ ប្រសិនបើត្រួយថ្មីចេញមានភាពយឺត ។ ការដាំដុះពូជកណ្តាល ឬ ពូជធ្ងន់ ត្រូវរៀបចំយុទ្ធសាស្ត្រឱ្យបានត្រឹមត្រូវដើម្បីគេចផុតពីមូសតែ ។ កត្តាចង្រៃនឹងអាចវិលមកវិញ ៣ ដង ក្នុងពេលរដូវដុះចេញមែកថ្មី ចេញផ្កា និង ផ្លែ នៅពេលចំការមានចំណីអាហារដូចជាកាកសំណល់សរីរាង្គ ។





សញ្ញាណមូសតែបំផ្លាញ





មូសតែដំណាក់កាលពេញវ័យ

**ខ វិធានការកំចាត់ និង ការពារ**

-ជំរុញឱ្យមានសត្វមានប្រយោជន៍ជាពិសេសស សត្វអង្រ្កង ដើម្បីធ្វើការកំចាត់មូសតែ។

-ដុតសំរាមបង្ហុយនៅលើខ្យល់ដើមដេញវាក្នុងរដូវបំផ្លាញរបស់សត្វមូសតែ

-ប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត គីណាល់ហ្វូស9២៥5 EC)- 0.05%, កាបារីល (50% WP)- 0.01% , ហ្វូស្វាមីដុង (85% WSC) - 0.03%

## ជង្គូវមូលស្លឹក

**ក លក្ខណៈបំផ្លាញ**

ដង្កូវប្រភេទនេះកើតពីមេអំបៅមួយប្រភេទ ដែលធ្វើការបំផ្លាញ ស្លឹកស្វាយចន្ទីនៅពេលស្លឹកខ្ចី ។ មេអំបៅពងដាក់ក្រោមស្លឹក នៅពេលវាញាស់ជាដង្កូវវាក៏មូលស្លឹកអោយកោងទៅមកនៅផ្នែកក្រោម និង លើនៃស្លឹកធ្វើអោយមើលឃើញជាខ្សែពណ៌សដូចហ្វីលជាផ្លូវខ្សែជាដុំដូចប្រជ្រុយ ។ បើស្លឹកចាស់ធ្វើអោយរបួសស្លឹក ហើយមុខរបួសនឹងដាច់ចេញ ។

**ខ វិធានការកំចាត់ និង ការពារ**

ការការពារ និង កំចាត់ គឺនៅពេលស្វាយចន្ទីចេញត្រួយត្រូវបាញ់ថ្នាំ ផូស ក្នុងកំរិត ២០ សេ.សេ ក្នុងទឹក ២០ លីត្រហើយ និង សេវីន ៤០-៥០ ក្រាម ក្នុងទឹក ២០ លីត្រ។ ការបាញ់ត្រូវធ្វើឡើងនៅពេលផ្កាមិនទាន់រីកបើមិនដូច្នោះវានឹងបំផ្លាញនូវសត្វល្អិតដែលជួយនាំលំអង ។

### ដង្កូវចោះផ្លែ

### ក លក្ខណៈបំផ្លាញ

ដង្កូវកើតឡើងពីមេអំបៅមួយប្រភេទដែលពងដាក់មែក និង កញ្ចុំផ្កានៅពេលពងញាស់បានជាដង្កូវនៅលើមែក ឬ លើកញ្ចុំផ្កាដោយបន្សល់ទុកនូវស្នាមជាខ្សែនៅតាមគន្លងដែលវាវារ។ ដង្កូវនេះនឹងចោះចូលក្នុងផ្លែ ឬ គ្រាប់ហើយធ្វើការបំផ្លាញផ្នែកខាងក្នុង ធ្វើអោយផ្លែស្វិតស្រពោនហើយជ្រុះឯគ្រាប់វិញនឹងវិវត្តន៍មិនប្រក្រតីគឺធ្វើអោយស្វិតហើយស្ងួត ។

### ខ វិធានការកំចាត់ និង ការពារ

នៅពេលស្វាយចន្ទីផ្តើមចេញផ្កា ត្រូវបាញ់ថ្នាំសំលាប់សត្វល្អិត ឈ្មោះអាសូទ្រីន ២០ សេ.សេ ក្នុងទឹក ២០ លីត្រ ។



**រូបសញ្ញាណនៃដង្កូវចោះផ្លែ និង គ្រាប់**

### ស្រឹងជញ្ជក់

### ក លក្ខណៈបំផ្លាញ

វាជាសត្រូវដ៏សំខាន់មួយចំពោះស្វាយចន្ទី ទាំងនៅជាដង្កូវ និង ពេញវ័យ ដែលធ្វើការជញ្ជក់រុក្ខរសពីស្លឹក ផ្កា និង ផ្លែខ្ចី ។ វាជញ្ជក់មានលក្ខណៈខុសៗគ្នា ដែលភាគច្រើនគេឃើញមានស្រមោចនៅទីនោះដែរ ព្រោះវាស៊ីស្រឹងនោះ។ បើសង្កេតឃើញស្រមោចនៅទីណា ប្រាកដជាមានស្រឹងនៅទីនោះ ហើយមានផ្សិតពណ៌ខ្មៅ ។ វាធ្វើការរាតត្បាតខ្លាំងនៅពេលអាកាសធាតុរាំងស្ងួត ។ស្រឹងនេះមានបីប្រភេទ ភាគច្រើនវាបំផ្លាញនៅតំបន់ត្រូពិកហើយប្រជាករវាកើន ឡើងនៅរដូវក្តៅ

**ខ វិធានការកំចាត់ និង ការពារ**

បើឃើញការបំផ្លាញរបៀបនេះ ត្រូវប្រើថ្នាំសំលាប់សត្វល្អិតអាសូឌ្រីន ១០-១៥ សេ.សេ លាយទឹក ២០ លីត្រ ឬប្រើថ្នាំ នូវ៉ាគ្រុន ១៥-២០ សេ.សេ លាយទឹក ២០ លីត្រ ឬ សេវិន ៤៥ ក្រាមលាយជាមួយទឹក ២០ លីត្រ បាញ់នៅពេលចេញ ត្រួយ ផ្កា និង ផ្លែ។ បាញ់ 0,0៥ ភាគរយ អង់ដូសុលហ្វាន់(ជាថ្នាំសំលាប់សត្វល្អិត)ឬ ផូស្វាមីដុងនៅ ពេលចេញពន្លកត្រួយ ដំបូង និង គ្រាប់ដំបូងវាមានឥទ្ធិពលក្នុងការការពារ ។

### ២.៧.៣ ស្មៅចង្រៃ

ការធ្វើស្មៅឡើងវិញ ច្រើនដងជាការល្អ រហូតដល់ដើមឈើមានម្លប់ បែកមែកសាខាគ្របទៅលើស្មៅ។ ដើម្បី កំចាត់ការលូតលាស់ស្មៅត្រូវសំអាត ២ ដង ក្នុង ១ ឆ្នាំ។ ការធ្វើស្មៅលើកទី១ ត្រូវអនុវត្តន៍មុនពេលភ្លៀងធំ ចំងាយ ២មពីដើមមេ ហើយស្មៅដែលសេសសល់ក្នុងចន្លោះត្រូវកាត់អោយខ្លី។ ការសំអាតស្មៅលើកទី២ ធ្វើឡើងនៅខែវិច្ឆិកា ដល់ខែធ្នូ ដើម្បីជួយសំរួលដល់ការប្រមូលផល។ បញ្ហា១សំខាន់មួយទៀតនៅក្នុងការដាំស្វាយចន្ទី គឺរុក្ខជាតិចង្រៃដែល កើតឡើងជាប្រចាំនៅក្នុងចំការនៅចន្លោះដើមមានរុក្ខជាតិចង្រៃ យើងត្រូវធ្វើការសំអាតវា ព្រោះវាជាប្រភពនៃការ ចំលង នូវជំងឺ និង ជាជំរកសត្វល្អិត ម្យ៉ាងទៀតបើមានរុក្ខជាតិចង្រៃនោះ វានឹងពិបាកក្នុងការចូលធ្វើការងារ មិនថាតែ ចំពោះការដាក់ជី ឬ ការប្រមូលផលឡើយ ។

វិធីកំចាត់រុក្ខជាតិចង្រៃនៅពេលដើមនៅតូច ១-២ឆ្នាំ គួរធ្វើការចំរះស្មៅក្នុងមួយឆ្នាំអោយបានពីរ ដង បើសិនផ្ទៃដីធំធេង គួរប្រើប្រាស់នៅថ្នាំកំចាត់ស្មៅចង្រៃ ដើម្បីចំណេញកំលាំងពលកម្ម ។

### ២.៧.៤ ការការពារភ្លើង

ជាកត្តាសំខាន់មួយក្នុងការដាំស្វាយចន្ទី គឺភ្លើងនឹងអាចឆេះនៅរដូវប្រាំងហែងក្រោយពេលអស់ទឹក ភ្លៀងត្រូវភ្ជួរ ឬជំរះស្មៅដើម្បីការពារភ្លើង ព្រោះមុនពេលអស់ទឹកភ្លៀងរុក្ខជាតិចង្រៃដុះច្រើន បើយើងជំរះវារួចយើង ទុកវាអោយរលួយជាជី ប៉ុន្តែវាមិនរលួយភ្លាមនោះទេ ដូច្នេះវាអាចបង្កអោយឆេះបានយ៉ាងងាយ ។

នៅពេលវាមានអាយុ ៨ ឆ្នាំ គួរពេន វាប៉ះគ្នានឹងធ្វើអោយវាម្លប់នឹងធ្វើអោយស្មៅវាមិនអាចដុះបាន ហើយមិនបាច់បារម្ភរឿងភ្លើងឡើយ ។

## ២.៨ ការប្រើប្រាស់ជី

### ២.៨.១ ជីកំប៉ុស្តិ៍

ដើមស្វាយចន្ទីដែលពេញវ័យបានផលិតម៉ាស់ស្ងួត ២០ គ.ក្រ ក្នុងមួយឆ្នាំ។ គួរដាក់បន្ថែមទៀតនូវជីកំប៉ុស្តិ៍ ៣៣ គ.ក្រ ឬ ៥0 គ.ក្រ នៃ FYM (កាកសំណល់នៅក្នុងកសិដ្ឋាន) មុនពេលខ្យល់មូសុងមកដល់។ ការដាក់ជីគួរដាក់ក្នុង កំរិត ១ ភាគនៃជីកំប៉ុស្តិ៍ ៣ ភាគស្លឹកឈើស្ងួត សម្រាប់រុក្ខជាតិនៅខ្ចី ហើយបន្ថែមបន្តិចម្តងៗ រហូតដល់រុក្ខជាតិ អាយុ៥ឆ្នាំ។ ជីកំប៉ុស្តិ៍ត្រូវដាក់ក្នុងរង្វង់សម្រាប់រុក្ខជាតិចាស់ (២០-៣០គក្រ) ហើយ គ្របគល់ដោយ សារធាតុសរីរាង្គ។ ប្រសិនបើមានសំរាមស្ងួតគួរតែផ្តល់មិនបាច់ធ្វើការបែងចែកជាដំណាក់កាល។ ការបាញ់ទឹកនោមគោ ១ លីត្រលាយ ទឹកធម្មតា ៦-១០ លីត្រ (១០:១០ ពង្រាវ) ឬ ជីកំប៉ុស្តិ៍ទឹក ១ លីត្រ លាយទឹកធម្មតា ៤0 លីត្រ (១០:៤០ពង្រាវ)

បាញ់លើស្លឹកត្រួយខ្ចី និង កញ្ចុំផ្កាជួយសំរួលដល់ការលូតលាស់បានល្អ ហើយក៏ទប់ទល់ជាមួយ ការវាយប្រហារពីជំងឺ និងកត្តាចង្រៃជាពិសេសសត្វមូសតែ ។




**ការប្រើប្រាស់ជីកំប៉ុស្តិ៍**

### ២.៨.២ ជីគីមី

ដំណាំស្វាយចន្ទីចូលចិត្តជីទ្រាប់បាត ឬ ជីកំប៉ុស្តិ៍ចាប់ពីមានអាយុ ៦ ខែ ដើម្បីជួយអោយវាមានការលូតលាស់ និង ដើមរឹងមាំ ចំពោះជីគីមីក៏អាចប្រើបានដែរ ។ បរិមាណជីត្រូវដាក់ទៅតាមអាយុកាល និង ទិន្នផល បើអាយុច្រើន ឬ នៅពេលបានទិន្នផលខ្ពស់ត្រូវប្រើអោយបានច្រើន ដើម្បីបំពេញបន្ថែមនៅការខ្វះខាត ។

**ក-ការប្រើប្រាស់ជី**

-នៅអាយុ ១-៣ ឆ្នាំ គួរប្រើប្រភេទជី ១២-២៤-១២ ដាក់កំរិត ២៥, ១០០ ឬ ២០០ ក្រាម ក្នុងមួយដើម

-នៅអាយុ ៤-៧ ឆ្នាំ ប្រើប្រភេទជី ១៥-១៥-១៥ ដាក់កំរិត ២០០-៣០០ក្រាម ក្នុងមួយដើម

-នៅអាយុ ៨ ឡើងប្រើប្រភេទជី ១៣-១៣-២១ ដាក់កំរិត ៣០០- ៥០០ ក្រាម ក្នុងមួយដើម

**ខ-របៀបដាក់ជី**

-ការដាក់ត្រូវពិនិត្យចុងមែកបើវាដល់ត្រឹមណាយើងត្រូវធ្វើការដាក់ជីត្រឹមនោះ ហើយការដាក់ត្រូវដាក់ជុំវិញដើម ដោយភ្ជួរកប់ ។

-ការភ្ជួរមិនត្រូវភ្ជួរអោយចូលជ្រៅទៅក្នុងរង្វង់នៃកំពែងជីកជុំវិញដែលស្ថិតនៅក្រោមមែកដែលបោះចេញឡើយ ព្រោះអាចប៉ះពាល់ដល់ឫសត្រូវបែងចែកជីជាបួនចំណែក ដោយ ៣ ចំណែកដាក់ជុំវិញកំពែងជីក និង មួយចំណែកទៀតដាក់ក្នុងជីទួលជុំវិញដើមតែមិនត្រូវដាក់អោយជិតដល់គល់ឡើយ ព្រោះអាចធ្វើអោយសំបកដងដើមរលួយ និង ធ្វើអោយងាប់ដើម យើងត្រូវដាក់ជីនៅតាមរង្វង់នៃកំពែង ព្រោះចុងឫសចាក់ចេញតាមខ្សែដេកបានប្រវែងកំពែង ហើយជាប្រភេទឫសស្រូបយកជីជាតិ សម្រាប់ចិញ្ចឹមដងដើម ។

**គ-ពេលវេលាដាក់ជី**

ការដាក់ជីត្រូវដាក់បីដងក្នុងមួយឆ្នាំ គឺ

-លើកទី១ នៅដើមរដូវភ្លៀង

-លើកទី២ នៅចុងរដូវភ្លៀង

-លើកទី៣ នៅពេលកាន់ផ្លែ គឺចុងខែ មករា និង ខែ កុម្ភៈ

ដោយពេលដាក់ជីរាល់លើត្រូវធ្វើការស្រោចទឹក ដើម្បីអោយជីរលាយជ្រាបចូលក្នុងដីហើយឫសអាចស្រូបយកជីតាមរយៈការស្រូបយកទឹកទាន់ពេល ។

## ២.៩ ការប្រមូលផល និងការកែច្នៃគ្រាប់ស្វាយចន្ទី

### ២.៩.១ ការប្រមូលផល

ជាប្រក្រតីស្វាយចន្ទីនឹងផ្ដើមឱ្យផលគ្រាដំបូងពេលអាយុ ២-៣ ឆ្នាំ ដោយផ្ដើមចេញផ្កាតាំងពីខែធ្នូ រហូតដល់ ខែ កុម្ភៈ អាស្រ័យទៅតាមពូជស្រាល កណ្ដាល និងធ្ងន់ គឺអាចប្រមូលផលនៅក្នុងខែកុម្ភៈដល់ខែឧសភា។ នៅក្នុងដើមមានផ្លែទុំមិនបានស្រុះគ្នាទេ ជាមធ្យមគឺប្រមូលផលយ៉ាងតិច ៤ ដង ដែលធ្វើឡើងតាមរយៈពេលមួយសប្ដាហ៍ ម្ដង។ ការប្រមូល ផលគួរប្រមូលផលយកផ្លែទុំ និងផ្លែដែលធ្លាក់នៅលើដី បើប្រមូលផលផ្លែដែលមិនទាន់ទុំល្អ គ្រាប់ដែលបានមកត្រូវស្វិតតូច គុណភាពទាប មិនអាចប្រើជាគ្រាប់ពូជបាន។

ការប្រមូលផលត្រូវប្រើកន្ត្រក ឬ ជាល ជៀសវាងធ្វើឱ្យផ្លែជាំសម្រាប់ការលក់ដូរនៅក្នុងស្រុកទាំងផ្លែ ទាំងគ្រាប់ តែបើចង់បានគ្រាប់ដែលមានគុណភាពល្អសម្រាប់ការនាំចេញ គួរទុកផ្លែឱ្យជ្រុះឯកឯងប៉ុន្តែត្រូវប្រញាប់ប្រឡេះគ្រាប់ចេញឱ្យទាន់ពេល ព្រោះអាចធ្វើឱ្យគ្រាប់ឆ្លងជំងឺស្វិតពីផ្លែ។ បន្ទាប់មកត្រូវយកទៅហាលថ្ងៃយ៉ាងតិច ៣-៥ ថ្ងៃ ដើម្បីបន្ថយសំណើមនៅក្នុងគ្រាប់ដោយរក្សាសំណើមមិនឱ្យលើសពី ១២ ភាគរយ ដើម្បីរក្សាទុកឱ្យបានយូរដោយមិនរលួយចោល។ បន្ទាប់មកត្រូវបែងចែកគ្រាប់លិចទឹក និងគ្រាប់អណ្ដែតទឹក ឬគ្រាប់តូចដាក់ដោយឡែក។

ផលិតផលក្នុងរយៈពេលកំពុងចំរើនលូតលាស់ធំគឺមានអាយុតិចនៅឡើយ វាឱ្យផលតិចហើយនឹងកើនឡើងជាបន្តបន្ទាប់រហូតដល់មានអាយុ ១០ ឆ្នាំ។ ស្វាយចន្ទីឱ្យផលឡើងចុះទៅតាមឆ្នាំ ដី និងការថែរក្សា ហើយអាស្រ័យអំណោយផលនៃអាកាសធាតុ។ នៅកន្លែងដែលមានដីជាតិល្អដីជ្រាបទឹកល្អ និងមានការថែរក្សាបានត្រឹមត្រូវ ដើមស្វាយចន្ទីអាចនឹងមានអាយុ ៧០-១០០ ឆ្នាំ តែទិន្នផលជាអតិបរិមា មិនលើសពី ២៥ ឆ្នាំឡើយ។ ជាមធ្យម ៣-៥ ឆ្នាំ ឱ្យទិន្នផល ប្រមាណ ១-៣ គ.ក្រ ក្នុងមួយដើម អាយុពី ៦-១០ឆ្នាំ ឱ្យទិន្នផលជាមធ្យម ៥-២០គ.ក្រ ក្នុងមួយដើម និងអាយុ ១០ឆ្នាំ ឡើងទៅឱ្យទិន្នផលជាមធ្យម ១០-៦០ គ.ក្រ ក្នុងមួយដើម។

### ២.៩.២ បច្ចេកទេសបកសំបកគ្រាប់ស្វាយចន្ទី

ឧស្សាហកម្មបកសំបកគ្រាប់ស្វាយចន្ទី ជាឧស្សាហកម្មដែលប្រើកំលាំងពលកម្មនៅក្នុងពេលអនាគតបានច្រើន គឺថា ជួយរកការងារឱ្យមនុស្សមួយចំនួនធំនៅក្នុងការងារបកសំបកគ្រាប់ស្វាយចន្ទី និង កោសសំអាតគ្រាប់រហូតដល់ការជ្រើសរើសគ្រាប់ទៅតាមខ្នាត និង ស្តង់ដារអន្តរជាតិដើម្បីនាំចេញទៅក្រៅ។ ការបកសំបកមួយផ្នែកធំ នៅប្រទេសវៀតណាម និង ថៃ គឺប្រើឧបករណ៍ប្រើដៃ ពោលគឺប្រើកំលាំងពលកម្ម នៅមិនទាន់បំពាក់គ្រឿងចក្រឱ្យពេញលេញ នៅឡើយ ហើយការងារនេះក៏ដូចនៅប្រទេសកម្ពុជាដែរ។ បញ្ហាសំខាន់ក្នុងការបកសំបកគឺក្រោយពេលបក រួចបានគ្រាប់ពេញលេញ មិនបែកបាក់ ហើយគ្រាប់មានពណ៌ស និង មានតំលៃខ្ពស់ជាងគ្រាប់ដែលបែកបាក់ឬគ្រាប់មានពណ៌ ស្រគាំ។

ដោយហេតុថាសំបកក្រៅរឹង ហើយពិបាកបក ដោយមិនឱ្យសាច់គ្រាប់បែកបាក់នោះគឺ នៅមានជ័រសំបកអាច បណ្តាលឱ្យមានបញ្ហាដល់ស្បែកបានទៀតផង។ ការបកសំបកគ្រាប់ស្វាយចន្ទី ឱ្យមានភាគរយសាច់គ្រាប់ខ្ពស់នោះត្រូវត្រៀម គ្រាប់សម្រាប់បក។ គេអាចធ្វើបានស្រួលដោយលីង ឬ បំពងគ្រាប់ តែបច្ចុប្បន្នរោងចក្រមានការរីកចំរើន ដោយធ្វើការស្ងោរគ្រាប់ ហើយយកគ្រាប់មកហាលឱ្យស្ងួតដែលអាចបន្ថែមប្រសិទ្ធិភាពដល់ការបកសំបក មិនឱ្យខូចដល់សាច់គ្រាប់ខាងក្នុង។ សម្រាប់សិប្បកម្មដែលមានលក្ខណៈគ្រួសារ វិធីដែលសមស្របដែលគេបានកែលំអកន្លងមក យើងបែងចែកទៅតាមលំដាប់លំដោយផ្សេងៗដូចជាៈ

**ការហាលគ្រាប់មុនពេលរក្សាទុក**

សំណើមគ្រាប់ស្វាយចន្ទីពេល ប្រមូលផលមានសំនើមខុសគ្នាទៅតាម អាកាសធាតុ កន្លែងផលិតសំនើមគ្រាប់ដែលហាល និង រយៈពេលនៅលើដីមុនពេលប្រមូលផល។ គ្រាប់ដែលមានសំនើមខ្ពស់នឹងធ្វើឱ្យកើតផ្សិតខ្សោះរសជាតិ និង ក្លិនជូរ ដែលធ្វើឱ្យគុណភាពធ្លាក់ចុះ។ សំណើមគ្រាប់នៅកន្លែងរក្សាទុកមិនឱ្យលើសពី ៩% ដែលអាចរក្សាទុក ដល់ ឆ្នាំ ដោយមិន ឱ្យគ្រាប់ខូចគុណភាពឡើយ។

ការហាលគ្រាប់ក្រោយពេលប្រមូលផល ជាកត្តាចាំបាច់ត្រូវធ្វើឱ្យបានសំរេច បើសិនមានការខូចខាតដោយសារសំណើមខ្ពស់មិនអាចកែលំអរបាន ដោយធ្វើការហាលឡើងវិញនោះទេ ។ ការហាលគ្រាប់ដោយកំដៅព្រះអាទិត្យ ធ្វើបាននៅ លើទីលានរាបស្មើមិនសើម ហើយត្រូវពង្រាយគ្រាប់ឱ្យស្តើងត្រូវពន្លឺបានសព្វ។

ការហាលគ្រាប់ ធ្វើឡើងដោយពេលវេលាផ្សេងៗពីគ្នា ទៅតាមទីកន្លែង អាកាសធាតុ និង សំណើមរបស់គ្រាប់។ សំណើមគ្រាប់ជាមធ្យម ១៣ ភាគរយ អាចហាលថ្ងៃរយៈពេល ៣ ថ្ងៃ និងធ្វើសំណើមចុះមកនៅត្រឹម ៩ ភាគរយ ដោយហាល ៨ ម៉ោង ក្នុងមួយថ្ងៃ ដែលក្នុងនោះសីតុណ្ហភាពបរិយាកាស ៣០ អង្សារសេ និង សំណើមបរិយាកាស ៧០ ភាគរយ។

**ការរក្សាទុក**

ការរក្សាទុកគ្រាប់ស្វាយចន្ទីធ្វើឡើងតាមរបៀបផ្សេងៗពីគ្នានៅលើផ្ទៃដែលស្ងួត។ គ្រាប់ដែលហាលរួចហើយអាចដាក់ក្នុងជាលប្ញស៊ីបានយូរតែបើផ្ទៃរក្សាមានសំណើមខ្ពស់ គេនិយមប្រើផ្ទៃរក្សាចាក់បេតុង និង ប្រក់ស័ង្កសីហើយធ្វើឱ្យខ្យល់អាកាសចេញចូលបានល្អ។ ការរក្សាទុកត្រូវយកចិត្តទុកដាក់ជាងគេទៅលើ " សំណើមរបស់គ្រាប់ ។

**ការត្រៀមគ្រាប់មុនធ្វើការបកសំបក**

ការត្រៀមគ្រាប់មុនពេលធ្វើការបកសំបក ជាកត្តាសំខាន់មួយ ព្រោះថា គ្រាប់ស្វាយចន្ទីមានសំបករឹងហើយស្វិតណាស់។ ការដែលមិនបានត្រៀមគ្រាប់ ឬក៏ត្រៀមគ្រាប់ខុស និងធ្វើឱ្យការបកសំបកមានការលំបាកហើយទទួលបានគ្រាប់បែកបាក់ចំពោះអ្នកបកដែលមិនសូវស្ទាត់ជំនាញ។

ការត្រៀមគ្រាប់ស្វាយចន្ទីមុនពេលបក គឺគេធ្វើការលីង តែឥឡូវគេប្រើវិធីស្ងោរ ប៉ុន្តែមានបញ្ហាចំពោះបរិស្ថាន ម្យ៉ាងវិញទៀតត្រូវការបច្ចេកទេសនៅកន្លែងផលិតឱ្យបានស្ទាត់ជំនាញ ព្រោះមានការកំណត់ពេលវេលា និង សីតុណ្ហភាពឱ្យបានច្បាស់លាស់ បើមានការប្រហែស នឹងត្រូវធ្វើឱ្យគ្រាប់ស្វាយចន្ទីខូចគុណភាព។ ក្រុមបច្ចេកទេសកសិកម្ម បានធ្វើការសិក្សាស្រាវជ្រាវកន្លងមកឃើញថា ការត្រៀមគ្រាប់ដោយការស្ងោរដែលជាវិធីប្រើនៅក្នុងរោងចក្រនៅប្រទេសថៃ និង វៀតណាម។ គេបានធ្វើការសាកល្បង ហើយឱ្យផលជាទីពេញចិត្តសម្រាប់ការត្រៀមគ្រាប់ទុក

ជាមុន គឺថាគ្រាប់ក្នុង និង សំបកគ្រាប់ញែកចេញពីគ្នា ហើយសំបកនោះមិនស្អិត ងាយស្រួលក្នុងការបក ម្យ៉ាងទៀត អ្នកដែលមិនសូវស្ទាត់ក៏អាចធ្វើបានដែរព្រោះការដាំទឹកឱ្យពុះមិនមែនជាការងារលំបាកឡើយ ។

វិធីត្រៀមគ្រាប់ដោយការស្ងោរមានលំដាប់លំដោយដូចតទៅ ដាំទឹកឱ្យពុះកញ្ជ្រោលហើយយកគ្រាប់មកដាក់ក្នុងឆ្នាំងទឹកកំពុងពុះនោះ រយៈពេល១៥នាទីក្រោយមកលើកឆ្នាំងទៅចាក់ផ្ទេរយកគ្រាប់ដាក់ចំរោះទឹក។ បន្ទាប់មកយកគ្រាប់នោះទៅហាលថ្ងៃ ១-២ ថ្ងៃ ដោយឱ្យគ្រាប់នៅមានសំណើមត្រឹម ៩ ភាគរយ ទើបយកគ្រាប់ទៅបក។

ចូរប្រយ័ត្នកុំដាក់គ្រាប់ច្រើនហួសប្រមាណ ព្រោះអាចធ្វើឱ្យសីតុណ្ហភាពទឹកថយខ្លាំង គួរបង្ខំភ្លើងឱ្យទឹកពុះកញ្ជ្រោលនៅពេលដាក់គ្រាប់ចូល (យកល្អគួរប្រើចង្រ្កានហ្គាស) ។ ពេលស្ងោរមិនចាំបាច់កូរឡើយ វាអាចធ្វើឱ្យខូចបង់បាន ព្រោះគ្រាប់នឹងកញ្ជ្រោលទៅតាមទឹកពុះដោយឯកឯង។ កុំស្ងោរគ្រាប់ឱ្យលើស ៥ នាទី ព្រោះធ្វើឱ្យគ្រាប់មានសំណើមខ្លាំងបណ្តាលឱ្យពន្យាពេលក្នុងការហាលថ្ងៃ។

**ការជ្រើសរើសគ្រាប់ស្វាយចន្ទីដោយម៉ាស៊ីនសម្រាប់បកសំបក**

រោងចក្រក្រៅប្រទេសគឺគេធ្វើឱ្យបានផលល្អ មិនថាប្រើកំលាំងមនុស្ស ឬ គ្រឿងម៉ាស៊ីនស្វ័យប្រវត្តិឡើយ គេត្រូវការជ្រើសរើសគ្រាប់ទៅតាមទំហំជាមុនសិន ឱ្យសមស្របទៅនឹងឧបករណ៍។ ការធ្វើឱ្យមានប្រសិទ្ធិភាពគឺជាកត្តាមួយបន្ថែមតំលៃទៅលើគ្រាប់។

គេបានបង្កើតប្រដាប់ជ្រើសរើសដោយងាយមួយ ដែលអាចជ្រើសរើសបានពីរទំហំ។ ការជ្រើសរើសនេះគឺធ្វើយ៉ាងណាឱ្យគ្រាប់ត្រូវនឹងមុខកាំបិតសម្រាប់បក ដើម្បីធ្វើឱ្យការបកមានប្រសិទ្ធិភាពខ្ពស់។ ក្រៅពីនេះគេអាចជ្រើសរើសគ្រាប់ ទៅតាមទម្ងន់គ្រាប់ ព្រោះទម្ងន់នេះអាចទាក់ទងទៅនឹងទំហំរបស់គ្រាប់ ។

ប្រដាប់ជ្រើសរើសទំហំគ្រាប់គឺប្រើកន្ត្រងមានខ្នាត១៦,៥ម.ម x ២៩ម.ម ដែលមានលទ្ធភាពជ្រើសរើសបាន ២00គ.ក្រ គ្រាប់ស្រស់ក្នុងមួយម៉ោង។ ប្រដាប់ជ្រើសរើសនេះមាន ២ ខ្នាត គឺគ្រាប់ដែលមានកំរាស់ 0-១៦ម.ម និង គ្រាប់ដែលមានកំរាស់ធំជាង ១៦ ម.ម មានលទ្ធភាពជ្រើសរើស ៩១,៥ % ។

ការជ្រើសរើស ទៅតាមទម្ងន់គ្រាប់ មាន២ខ្នាតដែរគឺទម្ងន់រវាង 0-៥ ក្រ ក្នុងមួយគ្រាប់ និងធំជាង ៥ ក្រ ក្នុងមួយគ្រាប់។ នៅពេលគេយកទៅបកសំបកគឺឱ្យត្រូវតាមខ្នាតគ្រាប់ និង មុខកាំបិតសម្រាប់បកយើងឃើញថាសកម្មភាពខាងលើមានប្រសិទ្ធិភាព ដល់ទៅ ៩៧,៥ភាគរយ។

**ការបកសំបកគ្រាប់**

ការបកសំបកគ្រាប់ស្វាយចន្ទីបានវិវត្តន៍ទៅតាមតំរូវការទីផ្សារអន្តរជាតិ។ បញ្ហាសំខាន់ចំពោះការបកសំបក គឺភាពមិនដូចគ្នានៃគ្រាប់ ។ យើងចង់បានគ្រាប់ដែលបកហើយមានលក្ខណៈល្អមិនបែកបាក់ និងមានពណ៌ស ល្អ ។ គេបានបង្កើតប្រដាប់បកសំបក ជាដំបូងមានដងសម្រាប់ ឆាក និង វិលប្រើដោយដៃឬជើង។

- ការបកសំបក គេត្រូវសង្កត់ផ្នែកកាំបិតទៅលើគ្រាប់ស្វាយចន្ទី ស្នាមពុះត្រង់ ហើយអាចមួលសំបកគ្រាប់ចេញបានយ៉ាងស្រួលរហ័សរហួន ហើយគ្រាប់មិនខូចសំបកខាងក្នុងផង។
- ប្រដាប់បកសំបក និងគ្រឿងបន្លាស់អាចធ្វើឡើង និងទិញបានដោយងាយ ចំណាយទុនតិចធ្វើអោយមានការកាត់បន្ថយនូវទុនក្នុងការបកសំបក ហើយរយៈពេលបង្វិលទុនបានឆាប់រហ័ស និងអាចបំពាក់នៅក្នុងរោងចក្រធំៗ បាន។ ងាយស្រួលប្រើប្រាស់មិនចាំបាច់អ្នកប៉ិនប្រសព្វពេកទេ។

- អាចប្តូរផ្លែកាំបិតនិង ទំរកាំបិតបានយ៉ាងងាយដើម្បីឱ្យសមស្រប និងគ្រាប់ពូជផ្សេងៗ ដែលរាប់បញ្ចូលទាំងទំហំគ្រាប់ដែលបានយកមកបកសំបក ។ ប៉ុន្តែផ្លែកាំបិតដែលមានទំហំខ្នាតទូទៅអាចប្រើក្នុងការបកសំបកគ្រាប់បានល្អស្ទើតែគ្រប់ទំហំខ្នាត ព្រោះគ្រាប់ដែលបានជ្រើសរើសមកមានទំហំប្រហាក់ប្រហែលគ្នា។
- រឺស័រដែលជាគ្រឿងបន្លាស់មួយបែបអាចទិញបានដោយងាយ តំលៃថោក ព្រមទាំងអាចទ្រទម្ងន់បានល្អហើយគេអាចធ្វើដងគំនាស់ធ្ងន់ និង រឹងមាំដើម្បីប្រើបានយូរ។

នៅប្រទេសថៃ និង វៀតណាមដែលគេមានប្រដាប់បកសំបក ដោយប្រើកំលាំងមនុស្ស។ ប្រដាប់បកសំបកប្រើកំលាំងមនុស្សគឺមានដងឆាកសង្កត់ចុះ ហើយក្រោយមកទៀតមានការវិវត្តន៍បន្តិចគឺប្រើជាន់ដោយជើង វាអាស្រ័យទៅលើ ភាពប៉ិនប្រសព្វរបស់អ្នកបក។ ប៉ុន្តែប្រដាប់បកសំបកដែលមានដងឆាកសង្កត់ចុះហើយមូរសំបក ចេញមិនចាំបាច់បច្ចេកទេស អ្វីឡើយនៅក្នុងការត្រៀមគ្រាប់ ឬអ្នកបកសំបកចំណានពេកទេ។ ប្រដាប់បកសំបកមួយប្រភេទទៀតធ្វើបានរហ័ស និង ប្រើដើមទុនខ្ពស់ហើយវាមិនសមស្របទៅនឹងស្ថានភាពប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ឡើយ។ ម្យ៉ាងទៀតប្រដាប់បកសំបកដែលមានដងឆាកសង្កត់ និង មូរសំបកចេញ ប្រភេទប្រើដោយដៃ និង ជាន់ដោយជើងជាប្រភេទមួយដែលសមស្របសម្រាប់ប្រទេសកម្ពុជា ព្រមទាំងជួយរកការងារឱ្យមនុស្សទៀតផង។

ក្រៅពីប្រដាប់បកសំបកខាងលើ មានប្រភេទចាស់មួយទៀតគឺប្រដាប់បកដោយប្រើកំលាំងយោលដែលប្រើបានស្រួល តែនៅមិនទាន់ធ្វើការកែច្នៃ ភាគច្រើនទទួលបានគ្រាប់បែកបាក់។ ប្រដាប់បកសំបកខាងលើត្រូវបានគេកសាងឡើងហើយយកមកសាកល្បងអំពីប្រសិទ្ធិភាពរបស់វាដែលប្រើល្បឿនវង្វិលបួនប្រភេទគឺ ៨00, ៩00, ១.000 និង ១.១00 ជុំ ក្នុងមួយនាទី ។ គ្រាប់ស្វាយចន្ទីត្រូវបានបែងចែកជាប្រាំខ្នាត ទៅតាមទម្ងន់គឺស្រាលជាង ៥,៥-៦ក្រ ៦-៧ក្រ ៧-៨ក្រ និង ធ្ងន់ជាង ៨ក្រាម ក្នុងមួយគ្រាប់ ហើយខ្នាតនីមួយៗយកទៅបន្ថែមសំណើមដោយត្រាំប្រេងរុក្ខជាតិដែល មានសីតុណ្ហភាព ១៨0អង្សារសេ រយៈពេល២នាទីកន្លះ ក្រោយមកច្របល់ជាមួយអង្កាមរហូតដល់ស្ងួត ។ បន្ទាប់មកយកទៅដាក់ចូលក្នុងចានយោល ធ្វើឱ្យវាចែកទៅតាមទម្ងន់គ្រាប់នីមួយៗ។

### ការដាក់គ្រាប់សំងួតក្នុងឡ

ការសំងួតគ្រាប់មានគោលបំណងធ្វើឱ្យសំបកក្នុងស្ងួតងាយស្រួលក្នុងការបក និង បានបន្ថយសំនើមគ្រាប់ព្រមទាំងអាចការពារសត្វល្អិត និង ផ្សិតក្នុងពេលស្តុក។ ក្រោយពីការសិក្សាកន្លងមកបានឱ្យជាបទពិសោធន៍គេគួរដាក់សំងួតក្នុងសីតុណ្ហភាព ៧0អង្សារសេ រយៈពេល ៣0-៤៥នាទី និង ធ្វើឱ្យគ្រាប់មានសំណើមត្រឹម ៤-៥ ភាគរយដែលសម ស្របទៅនឹងការបកសំបក។ បើសំនើមទាបជាងនេះនៅពេលបក និង ធ្វើឱ្យគ្រាប់បែកបាក់បាន។ ឡដែលគេប្រើសំងួត នៅប្រើចរន្តអគ្គិសនីដែលធ្វើឱ្យកំដៅថេរ ហើយផ្តល់កំដៅបានល្អ។

### ការបកសំបកក្នុង

ក្រោយពីបានសិក្សាឃើញថា ពូជស្វាយចន្ទីបានផលយ៉ាងច្រើនក្នុងការបកសំបកក្នុង ដែលក្រោយពីការសាកល្បងរួច អ្នកបច្ចេកទេសបានឱ្យដឹងថាការបកសំបកក្នុងបានដោយដៃ ឬប្រើកូនកាំបិតតូចៗជួយសំរួលក្រោយពេល

គ្រាប់ត្រូវបានកំដៅក្នុងឡ ។ វិធីនេះដើម្បីឱ្យគ្រាប់មានពណ៌សដូចគ្រាប់នៅស្រស់មិនទាន់ឆ្លងកាត់ការស្ងោរ និង កំដៅក្នុងឡ។

**ការជ្រើសរើសទំហំគ្រាប់មុនពេលស្តុក**

ការជ្រើសរើសទំហំគ្រាប់មុនពេលស្តុក គឺជាការជ្រើសរើសដោយដៃ ឬ គេប្រើកញ្ច្រែងដែលអាចញែកគ្រាប់ដែលល្អបាក់បែកខ្ទេច ពណ៌ស្រគាំចេញពីគ្នា បែកចេញទៅតាមលំដាប់ថ្នាក់នៃគ្រាប់ទៅតាមតំរូវការអ្នកទិញ។ ប៉ុន្តែបើបានជ្រើសរើសដោយលំដាប់ជ្រើសរើស អាចកាត់បន្ថយពេលវេលា និងកំលាំងពលកម្មបាន។

**ការជ្រើសរើសទំហំខ្នាតគ្រាប់ និងចាត់ថ្នាក់គុណភាព**

ការជ្រើសរើស និងការចាត់លំដាប់ថ្នាក់គ្រាប់ស្វាយចន្ទី ដើម្បីនាំចេញត្រូវធ្វើទន្ទឹមនឹងការបកសំបកក្នុង និង ចាត់លំដាប់ថ្នាក់ក្នុងការលក់ដូរ។ សាច់គ្រាប់បែងចែកជាបីពួកធំៗ គឺគ្រាប់ដែលមានពណ៌ស គ្រាប់មានពណ៌ខ្លោច និង គ្រាប់ស្វិត បាក់បែក ម្យ៉ាងទៀតគេអាចបែងចែកតាមរបៀបដូចតទៅនេះ ៖

**ក. ការបែងចែកទៅតាមទំហំគ្រាប់**

-គ្រាប់ដែលមានចំនួនគ្រាប់មិនលើស ១៥០ គ្រាប់ ក្នុងមួយគីឡូក្រាម

-គ្រាប់ទំហំកណ្តាលមានចំនួនមិនលើ ១៥១-២០០ គ្រាប់ ក្នុងមួយគីឡូក្រាម

-គ្រាប់តូចមានចំនួនគ្រាប់ច្រើនជាង ២០១ គ្រាប់ ក្នុងមួយគីឡូក្រាម

**ខ. ការបែងចែកទៅតាមចំនួនគ្រាប់**

-គ្រាប់ធំមានចំនួនមិនតិចជាង ២៥ ភាគរយ

-គ្រាប់កណ្តាលត្រូវមានគ្រាប់មិនតិចជាង ១៦-២៤ ភាគរយ

-គ្រាប់តូចត្រូវមានចំនួនតិចជាង ១៥ ភាគរយ

-គ្រាប់ខ្ទីត្រូវមានចំនួនមិនលើសពី ១៥ ភាគរយ

-កំទេចកំទីលាយជាមួយគ្រាប់មិនលើស ១ ភាគរយ

-សំណើម ត្រូវមានសំណើមគ្រាប់មិនតូចជាង ៨ ភាគរយ

ការលក់ដូរសាច់គ្រាប់ស្វាយចន្ទីទៅក្រៅប្រទេសត្រូវចាត់ថ្នាក់ទៅតាមស្តង់ដាពិភពលោក ដោយបែងចែកជា ២២ លំដាប់ថ្នាក់ ៖

-ថ្នាក់ទី ១ មានសាច់គ្រាប់ពេញលេញ ២១០ គ្រាប់ក្នុងមួយផោន = 0, ៤៥៣ គ.ក្រ

-ថ្នាក់ទី ២ មានសាច់គ្រាប់ពេញលេញ ២៤០ គ្រាប់ក្នុងមួយផោន = 0,៤៥៣ គ.ក្រ

-ថ្នាក់ទី ៣ មានសាច់គ្រាប់ពេញលេញ ២៨០ គ្រាប់ក្នុងមួយផោន = 0,៤៥៣ គ.ក្រ

-ថ្នាក់ទី ៤ មានសាច់គ្រាប់ពេញលេញ ៣២០ គ្រាប់ក្នុងមួយផោន = 0,៤៥៣ គ.ក្រ

-ថ្នាក់ទី ៥ មានសាច់គ្រាប់ពេញលេញ ៤០០ គ្រាប់ក្នុងមួយផោន = 0,៤៥៣ គ.ក្រ

-ថ្នាក់ទី ៦ មានសាច់គ្រាប់ពេញលេញ ៤៥០ គ្រាប់ក្នុងមួយផោន = 0,៤៥៣ គ.ក្រ

-ថ្នាក់ទី ៧ មានសាច់គ្រាប់ពេញលេញ ៥០០ គ្រាប់ក្នុងមួយផោន = 0,៤៥៣ គ.ក្រ

-ថ្នាក់ទី ៨ មានសាច់គ្រាប់ពេញលេញ តែមានចំនុចខ្លោចលាយនៅលើគ្រាប់

-ថ្នាក់ទី ៩  មានសាច់គ្រាប់ពេញលេញតែគ្រាប់បែកជាពីរកំល្លែប

-ថ្នាក់ទី ១០  មានសាច់គ្រាប់ពេញលេញលាយភាគច្រើន តែមានគ្រាប់បែកជា២ លាយជាមួយ

-ថ្នាក់ទី ១១ មានសាច់គ្រាប់ពេញលេញភាគច្រើន តែមានគ្រាប់បែកបាក់លាយជាមួយច្រើនឡើង

-ថ្នាក់ទី ១២  ជាគ្រាប់បាក់បែកបន្តិចបន្តួចគ្រប់គ្រាប់ទាំងអស់ជាចំណិតធំៗ

-ថ្នាក់ទី ១៣  ជាគ្រាប់បាក់បែកបន្តិចបន្តួចគ្រប់គ្រាប់ទាំងអស់ជាចំណិតតូចៗ

-ថ្នាក់ទី ១៤  ជាគ្រាប់បាក់បែក បាក់ច្រើនណាស់

-ថ្នាក់ទី ១៥  គ្រាប់មានពណ៌ខ្មៅចខ្លាំង

-ថ្នាក់ទី ១៦  គ្រាប់មានពណ៌ខ្មៅចខ្លាំងច្រើនថែមទៀត

-ថ្នាក់ទី ១៧  មានគ្រាប់ខ្មៅច និង បែកបាក់

-ថ្នាក់ទី ១៨  មានគ្រាប់ខ្មៅចជាដុំគ្រាប់តូចៗ

-ថ្នាក់ទី ១៩  មានគ្រាប់ខ្មៅចច្រើន និង ដុំតូចៗច្រើនឡើង

-ថ្នាក់ទី ២០  មានគ្រាប់ខ្មៅច និងបែកបាក់លាយច្រើន

-ថ្នាក់ទី ២១  មានគ្រាប់ខ្មៅច និងបែកបាក់លាយច្រើនជាង

-ថ្នាក់ទី ២២  មានគ្រាប់ខ្មៅច និងបែកបាក់កាន់តែច្រើន

នៅក្នុងការលក់ដូរគ្រាប់ស្វាយចន្ទីស្រស់នៅក្នុងចំណាត់ថ្នាក់ទីផ្សារ និងការលក់ទូទៅគ្មានការធានាទេ ព្រោះគេនិយមលក់ផលិតផលដូច្នេះ រហូតដល់ ៨២ភាគរយនិងលក់ក្នុងរូបភាពបែងចែកចំណាត់ថ្នាក់តែ១៨ ភាគរយ ប៉ុណ្ណោះ។

នៅពេលបកសំបកហើយវាសមស្របសម្រាប់លក់រាយ និងលក់ដុំ ឬលក់ចេញទៅក្រៅប្រទេស។ ក្នុងការស្តុកសាច់គ្រាប់មានការបែងចែកថ្នាក់ដើម្បីកំណត់តំលៃ សម្រាប់ការលក់រាយ ការស្តុកក្នុងថង់ប្លាស្ទិកមួយគីឡូក្រាម ឬកន្លះគីឡូក្រាម អាចដាក់ក្នុងកេសឈើប្រមាណ ៥០ គីឡូក្រាម និងនាំចេញក្រៅប្រទេស។

ចំពោះផលិតផលសម្រាប់នាំចេញទៅក្រៅ ត្រូវតំរូវទៅតាមស្តង់ដាផ្សារពិភពលោក ដូចជាសំណើមនៅចន្លោះ ពី ៣-៦ ភាគរយ។ចំពោះសំណើម ៣ ភាគរយ ដែលធ្វើឱ្យគ្រាប់បាក់បែកងាយ ប៉ុន្តែសំណើម ៦ភាគរយ នឹងត្រូវ បំផ្លាញដោយសារមីក្រុប និង ផ្សិត ដូច្នេះត្រូវកែតំរូវសំណើមឱ្យបានសមស្រប គឺ ៥ ភាគរយ ដាក់ក្នុងបន្ទប់បិតជិត ស្តុកគ្រាប់ក្នុងកេសស្ពោរបិទជិតហើយបញ្ចូល ឧស្ម័នកាបូនិក ឬ នីត្រូសែន នឹងជួយឱ្យគ្រាប់ជៀសផុតពីផ្សិត មីក្រុប ឬមានក្លិនជូរឡើយ ព្រមទាំងជួយឱ្យគ្រាប់មិនបាក់បែក នៅពេលដឹកជញ្ជូន។

ដើម្បីបន្ថែមអត្រាគ្រាប់ពេញលេញឱ្យបានខ្ពស់ ត្រូវធ្វើផ្លែកាំបិតឱ្យត្រូវនឹងលក្ខណៈរបស់គ្រាប់។ អត្រាគ្រាប់ពេញលេញខ្ពស់ គឺធ្វើឡើងនូវផ្លែកាំបិតដែលមាន ២ ខ្នាត គឺខ្នាតធំ និងតូចសម្រាប់ប្រើជាមួយគ្រាប់ដែលបានជ្រើសរើសដោយកន្រ្តង ។ នៅក្នុងការបកសំបកត្រូវបែងចែកថាសដាក់គ្រាប់ជាពីរផ្នែកគឺថាសគ្រាប់ពេញលេញ ថាសគ្រាប់បាក់បែកជាពីរ និងគ្រាប់ខ្មៅច ដើម្បីងាយស្រួលធ្វើចំណាត់ថ្នាក់ក្នុងការលក់ដូរ។

## ២.១០ ការស្តុកផលិតផលស្វាយចន្ទី

ប្រសិនបើជាការស្តុកសម្រាប់លក់នៅក្នុងប្រទេសរយៈពេលខ្លីគឺអាចរក្សាបាន ដោយដាក់នៅក្នុងថង់ប្លាស្ទិកហើយចងមាត់ឱ្យណែនមិនឱ្យខ្យល់ចូលក៏អាចរក្សាគ្រាប់បានមួយរយៈដែរ ។ ប៉ុន្តែបើស្តុករយៈពេលយូរដូចជាការលក់ទៅ

ក្រៅប្រទេសត្រូវមានការស្តុកក្នុងសុញ្ញអាកាស ឬក៏ដាក់ទៅក្នុងអ្វីមួយតូចបូមខ្យល់ចេញឱ្យអស់រួចបិតឱ្យជិតហើយបញ្ចូល ឧស្ម័នកាបូនិក និង នីត្រូសែន។ បច្ចុប្បន្នការស្តុករយៈពេលយូរមាន ៤ប្រភេទ ៖

ក. ការធ្វើជាកំប៉ុង

ខ. ច្រកក្នុងកែវ ឬក្រឡ

គ. ច្រកក្នុងថង់ប្លាស្ទិកទាំងមូល

ឃ. ប្រភេទកូរឱ្យម៉ត់ដាក់ក្នុងថង់ប្លាស្ទិកជាដំណាប់ (ផ្លែ)

សារៈប្រយោជន៍នៃការស្តុកក្នុងសុញ្ញអាកាស ៖

-ដើម្បីរក្សាភាពស្រួល

-ជួយពន្យាអាយុឱ្យបានយូរ និងរក្សាពណ៌សម្បុរឱ្យបានល្អដូចដើម

-ជួយបន្ថែមគុណភាពព្រោះបច្ចុប្បន្នអតិថិជនចាប់អារម្មណ៍ទៅលើគុណភាព។ ទោះបីជាការស្តុកក្នុងអាកាសនេះមិនបានធ្វើឱ្យតំលៃកើនជាងនេះក៏ដោយ។ គ្រាប់ដែលបានស្តុកទុកមានសំនើម ៥% ប្រសិនបើសំនើមទាបជាងនេះ ដែលធ្វើ ឱ្យគ្រាប់ងាយបាក់បែក ឬបើខ្ពស់ជាងនេះ អាចត្រូវបំផ្លាញដោយសត្វល្អិត និងផ្សិត ជាប្រក្រតីគ្រាប់ដែលបាន ចូលឡកំដៅហើយបកសំបកក្នុងចេញមានសំណើមប្រមាណ៥ ភាគរយ។

## ២.១១ បច្ចេកទេសនៃការបកសំបក ការថែរក្សា និង ការស្តុកគ្រាប់ស្វាយចន្ទីសខ្ទេប

គ្រាប់ស្រស់

១.បង្កាត់ភ្លើងភ្លើង

២.លីងជាមួយខ្សាច់

៣.បំពងដោយប្រេងរុក្ខជាតិ

៤.ត្រាំទឹក ៥ ម៉ោងហាលថ្ងៃមួយថ្ងៃ

៥.ស្ងោររយៈពេលល ៣០ នាទី ហាលថ្ងៃមួយម៉ោង

៦.ស្ងោររយៈពេលល ៣០ នាទី

៧.ហាលរយៈពេលមួយថ្ងៃ

ការបកសំបក

១.ច្រៀកឬពុះដោយកាំបិត

២.ពុះដោយកាំបិតមុត

៣,៤,៥.បកសំបកដោយប្រើឱ្យឧបករណ៍មានផ្លែ

កាំបិតមួយ ផ្លែកាំបិតមួយគូរភ្ជាប់គ្នា

៦.ការបកសំបកដោយឧបករណ៍ដែមានកាំបិតមួយ

៧.បកសំបកដោយអាររាងដូចវង់ខែហាលថ្ងៃ

សំងួតដោយឡ៦០-៨០អង្សាសេរយៈពេល១២-

២៤យៈពេល១២-២៤ម៉




ឧបករណ៍បកសំបកគ្រាប់ស្វាយចន្ទី

# ប្រដាប់ឆាកសំបកគ្រាប់ស្វាយចន្ទី និង ផ្លែករួមផ្សំ




| | | | |
|---|---|---|---|
| ១ | ជើងទំរ | ៧ | ទំរកាំបិតខាងលើ |
| ២ | ដែកកន្ទុយត្រី | ៨ | អ័ក្សទ្រកាំបិតខាងលើ |
| ៣ | អ័ក្ស | ៩ | ដងសំរាប់ឆាក |
| ៤ | ទំរកាំបិត | ១០ | ដងបំណាក |
| ៥ | កាំបិតខាងក្រោម | ១១ | វីស័រ |
| ៦ | កាំបិតខាងលើ | ១២ | កន្លែងមូលខ្មៅភ្ជាប់ដង |

ឧបករណ៍បកសំបកគ្រាប់ និង វត្ថុផ្សំ

## ២.១២ ការកែច្នៃ

### ២.១២.១ ការធ្វើទឹកស្វាយចន្ទី

ជ្រើសរើសយកផ្លែដែលទុំ តែមិនទាន់ជ្រុះនៅឡើយ យកមកប្រឡេះយកគ្រាប់ចេញពីគ្នា។ យកផ្លែលាងទឹកឱ្យស្អាតហើយចំហុយក្នុងរយៈពេល ៥-១០នាទីទុកឱ្យត្រជាក់រួចច្របាច់ដោយប្រដាប់ច្របាច់ទឹកផ្លែឈើ ហើយត្រងឱ្យស្អាតបន្ថែម ហ្សេលែទីន (អលោតិន) បន្តិចកូឱ្យសព្វ រួចទុកចោល ១៥ នាទី ក្រោយមកត្រងម្តងទៀតនឹងបានទឹកថ្លាស្អាតហើយ យកទៅដាក់ក្នុងកែវ។ ការដាក់ក្នុងកែវមានពីរវិធី ៖

-យកទឹកស្វាយចន្ទីដែលបានត្រៀមទុកមកកំដៅ ៩០-៩៥អង្សារសេ ហើយដាក់ទៅក្នុងកែវស្អាតបិតឱ្យជិត។ យកទៅសំលាប់មេរោគក្នុងទឹកក្តៅ ៨៥-៩០ អង្សារសេ រយៈពេល ៣០ នាទីហើយទុកឱ្យត្រជាក់។

-យកទឹកស្វាយចន្ទីមកកំដៅ ៧០ អង្សារសេ បន្ថែម សូដ្យូមបង់ស្សូឡាត (Benzolate)ក្នុងអត្រា មិនលើសមួយក្រាមជាមួយទឹកស្វាយចន្ទីមួយលីត្រ ហើយដាក់ទៅក្នុងកែវបិតជិត។

### ២.១២.២ ការធ្វើទឹកស្វាយចន្ទីឱ្យក្រាន់តែមានរសជាតិ

យកស្វាយចន្ទីដែលទុំល្អ មកប្រឡេះគ្រាប់ចេញ ហើយយកទៅលាងទឹកឱ្យស្អាត ហើយត្រៀមទឹកស្វាយចន្ទីដូចករណីខាងលើ។ យកស្ករពីរពែងដាំជាមួយទឹកមួយពែង ផ្សំជាមួយទឹកស្វាយចន្ទីដែលត្រៀមទុកប្រមាណមួយស្លាបព្រាតែ និង បន្ថែមអាស៊ីតស៊ីទ្រិចមួយស្លាបព្រាតែ រហូតដល់ជូរល្មម បន្ថែមអំបិលឱ្យមានរសជាតិប្រៃហើយដាក់ទៅក្នុងកែវ។

### ២.១២.៣ ការធ្វើដំណាប់ស្វាយចន្ទី

យកផ្លែស្វាយចន្ទីដែលទុំធ្លាក់នៅលើដី មកប្រលេះយកគ្រាប់ចេញ លាងទឹកឱ្យស្អាត ហើយត្រាំទឹកអំបិលអត្រា ២ ភាគរយ នៃទម្ងន់ផ្លែស្វាយចន្ទីរយៈពេល ៣ ថ្ងៃ។ ក្រោយមកលាងឱ្យស្អាតយកទៅចំហុយនៅក្នុងឆ្នាំងរយៈ ពេល ១០-១៦ នាទី ។ បន្ទាប់មកកាត់ជាដុំតូចៗនិងថែមស្ករមួយគីឡូក្រាមជាមួយសាច់ផ្លែ ១គីឡូក្រាមយកទៅរំងាស់ឱ្យខាប់ល្មម ហើយបន្ថែមអាស៊ីតស៊ីទ្រិចមួយស្លាបព្រាតែរួច ដាក់ក្នុងកែវក្រឡ។

### ២.១២.៤ ការធ្វើទឹកខ្មេះ

គ្រឿងផ្សំរួមមាន: ទឹកស្វាយចន្ទី ៣ លីត្រ ទឹកស្អាត ៦ លីត្រ ស្ករ ១គ.ក្រ មេដំបែរ១ស្លាបព្រាតែនិងមេទឹកខ្មេះ១ស្លាបព្រាតែ។ ហាន់ផ្លែស្វាយចន្ទីដែលលាងស្អាតជាដុំតូចៗ រួចគាបយកទឹកត្រងឱ្យស្អាតបន្ថែមទឹក និង ស្ករ រួចស្ងោរឱ្យពុះរយៈពេល ១០នាទី។ ត្រងដោយស្បៃដាក់ទៅក្នុងកែវហើយបែងចែកទឹកស្វាយចន្ទីដែលត្រៀមទុក ២៥០ម.ល ដាក់មេដំបែរហើយក្រឡុក។ ក្រោយពេលមេដំបែរធ្វើសកម្មភាពយើងឃើញមានពពុះកើតឡើង។ ចាក់ផ្ទេរទឹកស្វាយចន្ទីចូល ទៅក្នុងទឹកស្វាយចន្ទីដែលត្រៀមទុកខាងលើហើយផ្អាប់ទុករយៈពេល ៧-១០ ថ្ងៃ ។ បន្ទាប់មកទៀតបន្ថែមទឹកខ្មេះ ១០ភាគរយ (មេទឹកខ្មេះជាទឹកខ្មេះដែលបានផ្អាប់ទុកពីលើកមុន) ត្រាំតទៅទៀតរយៈពេល ៣០-៤៥ ថ្ងៃ ហើយផ្ទុកមួយរយៈឱ្យជំ និង មានក្លិនល្អ។ បើត្រូវការធ្វើឱ្យថ្លាឆាប់រហ័សត្រូវត្រងហើយយកទៅកំដៅ

ដើម្បីសំលាប់មេរោគ នៅសីតុណ្ហភាព ៦០ អង្សាសេ រយៈពេល ៣០ នាទី ហើយយកទៅបន្ថែមពណ៌លឿង បន្តិចជាការស្រេច។

### ២.១៣ ការពង្រីកពូជស្វាយចន្ទី

**ការជ្រើសរើសពូជដែលមានទិន្នផលខ្ពស់**

ភាគច្រើននៃពូជដែលបានរំដោះដោយស្ថានីយ៍ស្រាវជ្រាវគឺមិនមានបញ្ហាអ្វីទេក្នុងការជ្រើសរើសពូជ។ កសិករអាចធ្វើការសង្កេតតាមដាននិងអាចធ្វើការជ្រើសរើសពូជដោយខ្លួនគាត់ដោយផ្ទាល់។ ការជ្រើសរើសគឺត្រូវដាក់ឈ្មោះផ្តល់នូវអត្តសញ្ញាណហើយបន្តធ្វើឱ្យមានចំនួនពូជនេះកើនឡើងច្រើន គួរតែធ្វើលើសរីរាង្គលូតលាស់របស់វាពោលគឺធ្វើតាមរយៈការបំបៅឬ ផ្សាំមែក។ យោងតាមការវិនិច្ឆ័យនេះយើងអាចធ្វើការជ្រើសរើសនៅលើដើមណាដែលបានផ្តល់ទិន្នផលខ្ពស់ និង មានលក្ខណៈដូចខាងក្រោមៈ

-រុក្ខជាតិមានការលូតលាស់លឿន មែកបែកសាខានិងស្រឡះល្អ

-ត្រូវមានកញ្ចុំផ្កាពី ១០-៣០ កញ្ចុំក្នុង ១ ម៉ែត្រការ៉េ។ ចំនួនកញ្ចុំផ្កាច្រើនគឺមានសក្តានុពលនៃទិន្នផល។

-ផ្កាទ្វេភេទដែលមានចំនួនពី ១០-៣០០។ ចំនួនផ្កាទ្វេភេទច្រើន គឺបានទិន្នផលច្រើន។

-ទម្ងន់គ្រាប់ ជាមធ្យម ៧ ក្រាម ក្នុងមួយគ្រាប់

-រុក្ខជាតិត្រូវចាប់ផ្តើមចេញផ្កា (មករា-កុម្ភៈ) ឬ (កុម្ភៈ-មីនា)ដើម្បីជៀសផុតពីពួក **មូសតែ។** រដូវ ចេញផ្កាមានរយៈពេលខ្លី (១-៣ខែ)។

-ដើមឈើត្រូវតែមានភាពធន់ទ្រាំនឹងការបំផ្លាញសត្វល្អិត និង ជំងឺ

-ភាគរយនៃទិន្នផលគ្រាប់ត្រូវតែច្រើនជាង ២៨ % នៃគ្រាប់ទាំងមូល

-ដើមឈើពេញវ័យល្អ (អាយុ ១៥ឆ្នាំ ឬលើសនេះ) ត្រូវតែផ្តល់ផលពី ១៥-២៥ គ.ក្រ។

-ចំពោះដើមដែលដាំនៅដាច់តែឯងផ្តល់ផលប្រហែលជាក្នុងមួយដើម ផ្តល់ផលបាន ៥០-៦០ គ.ក្រ។

**ការបន្តពូជតាមសរីរាង្គលូតលាស់**

ភាគច្រើននៃចំការស្វាយចន្ទីចាស់ៗ ត្រូវបានបង្កើតឡើងដោយការដាំកូនដែលបណ្តុះពីគ្រាប់ ។ រុក្ខជាតិដែលបានមកមិនមានលក្ខណៈជាឯកសណ្ឋានភាព ដូច្នេះដើម្បីទទួលបានជោគជ័យក្នុងបញ្ហានេះ គេត្រូវធ្វើការបំ-បៅ ដោយធ្វើការជ្រើសរើសមែកពូជដែលមានគ្រាប់ធំហើយទិន្នផលជាមធ្យម ច្រើន ជាង ១០ គ.ក្រ ក្នុងមួយដើមក្នុងមួយឆ្នាំ អាចជ្រើសរើសសម្រាប់ការបង្កើនចំនួនស្វាយចន្ទីនេះ។

វិធីសាស្ត្រផ្សាំ និងបំបៅសរីរាង្គខ្ចី គឺជាវិធីសាស្ត្រពីរដែលអាចធ្វើបានសម្រាប់បង្កើននូវចំនួនកូនរុក្ខជាតិដោយប្រើប្រាស់សរីរាង្គលូតលាស់។ ចំណែកការផ្សាំ និង បំបៅ អាចធ្វើបានដោយកសិករធម្មតា។ វិធីសាស្ត្រទាំងពីរនេះ គឺមានការចំណាយច្រើនជាង ការដាំដោយគ្រាប់ ហើយត្រូវមានការអនុវត្តន៍ និង ការគ្រប់គ្រងរោងបណ្តុះឱ្យបានល្អ ។

**ក. វិធីសាស្ត្រសាកមែក**

ជ្រើសរើសមែកពូជណាដែលពេញវ័យល្អមានទំហំប្រហែលម្រាមដៃ ត្រូវមានប្រវែង ៣០-

៤០ ស.ម ពីខាងចុងនៃមែក ។ មែកនោះត្រូវចិតយកសំបកឈើ ដោយក្រឡឹងជុំវិញមែកប្រវែង ២,៥ ស.មយកវាចេញដោយថ្នមៗបន្ទាប់មកកោសរំអិលវាចេញ ។ បំណែកស្រកីដូងម៉ត់ ឬអាចម៍រណាដែលផ្សើមរួចដាក់ឱ្យចំមុខដែលចៀរសំបកដែលមានទទឹង ១០ ស.ម ដោយប្រើបន្ទះប្លាស្ទិក (គេប្រើនៅរដូវប្រាំង) ឬ ក្រណាត់កូតុងស្តើងៗ ហើយផ្សើមកន្លែងចងនោះ ។

ឫសនឹងលេចចេញក្នុងកំឡុងពេលពី ៤៥-៦០ ថ្ងៃ ក្រោយពេលផ្សាំ។ ពេលឫសដុះចេញ ដកប្លាស្ទិកចេញ ហើយកាត់ភាគខ្លះនៅគល់ ។ ក្រោយរយៈពេលមួយអាទិត្យ ប្រសិនបើស្លឹកដែលសាកនោះ នៅមានពណ៌បៃតង យើងអាចកាត់មែកនោះចេញមកត្រៀមដាំបាន។ ដើមដែលដុះឫសចេញមកនេះរក្សាទុកនៅក្នុងរោងបណ្តុះដោយមានម្លប់ ៥០ភាគរយ។ ការដាំដុះដោយសាករបៀបនេះ គប្បីថៃទាំឱ្យបានត្រឹមត្រូវល្អ ជៀសវាងការបំផ្លាញពីកត្តាផ្សេងៗ ដល់ឫសខ្ចី ដែលទើបតែដុះថ្មី។



ជ្រើសរើសមែកល្អ



ចិតសំបកខាងក្រៅមែក



ស្រកីដូងរុំកន្លែងចិត



ចងប្លាស្ទិករុំភ្ជិត



បាវក្រចៅរុំភ្ជិត



ចិតមែកបន្តិចម្តងៗរហូតដល់ដើមចេញឫសមាំទាំ



កាត់ទុកដាំ

**ខ.ការតត្រួយ(នៅលើដើមធំដែលមានអាយុពី ៤៥ ថ្ងៃ ទៅ ៦០ ថ្ងៃ)**

បច្ចេកទេសត្រឹមត្រូវនៃការបំបៅសវីរាង្គខ្ចីគឺមានលំអិតដូចខាងក្រោមៈ

-កូនចន្ទីមានអាយុ ៤៥-៦០ ថ្ងៃ ដែលបានបណ្តុះនៅក្នុងថង់ប្លាស្ទិក (បណ្តោយ ២៥ ស.ម x ១៥ ស.ម កំរាស់ 0,0៣ ស.ម ) ប្រើប្រាស់ជាគល់ទំរ។

-បន្ទាប់ពីការជ្រើសរើសពន្លកពូជដែលដុះលូតលាស់ថ្មីៗ(គ្មានផ្កាមានអាយុពី៣-៥ខែ ) ត្រូវយកហើយត្រូវធ្វើការចៀរសំអាតលើដើមមេ ដោយកាត់តួស្លឹកចេញ ទុកតែទងស្លឹកជាប់នឹងដើម។ បន្ទាប់ពី អាយុបាន១០-១៥ថ្ងៃ ពន្លកដែលបានសំអាតត្រូវបាន គេប្រមូលយកកំណាត់ភ្នែកទៅប្រើសម្រាប់បំបៅ។

-គល់ទំរត្រូវបានរៀបចំដោយធ្វើការកាត់ចោលស្លឹកទាំងអស់ ដោយទុកតែពីរគូរនៅស្លឹកខាងក្រោមបង្អស់ ។ ការលូតលាស់ផ្នែកចុង(ផ្នែកសរីរាង្គខ្ចី) ដែលមានកំពស់ចាប់ពីក្រោមទៅលើ ១៥ ស.ម ត្រូវច្រៀកដើមអោយមានប្រវែង ៥-៦ ស.ម។

-ត្រួយពូជដែលបំបែកចេញពីដើមមេនោះ ត្រូវយកទៅស៊កភ្ជាប់ចូលទៅក្នុងសំបកឈើដែលយើងបានកាត់ឆ្វតខាងលើប្រវែង ៥-៦ ស.ម ។

-សៀតត្រួយពូជចូលទៅក្នុងស្នាមឆ្វតដែលស្ថិតនៅលើគល់ទំរដោយប្រុងប្រយ័ត្នគឺលៃយ៉ាងណាឱ្យស្រទាប់រំអិល (ជាមប៊ុម)របស់ដើមទំរ និងត្រួយពូជត្រូតស៊ីគ្នា។

-កន្លែងបំបៅត្រូវបានចងភ្ជាប់ដោយបង់រុំ(ទំហំ ១.៥ ស.ម ប្រវែង ៣0 ស.ម និង កំរាស់ 0,0១ ស.ម )។

-ថង់គ្រប(ទំហំ ២0 ស.ម x ៤ ស.ម និង កំរាស់ 0,0២ ស.ម) គឺគ្របទៅលើរុក្ខជាតិដែលបានបំបៅរួចដើម្បីការពារពន្លកនេះមិនអោយស្ងួត ។

-ការតត្រួយគួរប្រព្រឹត្តទៅក្រោមម្លប់ក្នុងរោងបណ្តុះ បន្ទាប់មកយកដើមដែលតត្រួយនោះទៅទុកនៅក្នុងម្លប់ប្រហែលជា ១៥ ថ្ងៃ ហើយផ្ទេរទៅកន្លែងដែលមានខ្យល់អាកាសគ្រប់គ្រាន់។

-រាល់មែកបំបៅត្រូវមើលការថែទាំនៅថ្នាល រហូតដល់រដូវដាំដុះលើកក្រោយ ។ មែកបំបៅរួចនឹងត្រូវធ្វើការដាំដុះបន្ទាប់ពីបំបៅបានពី ៥-៦ ខែ ដាច់ខាត។



មែកភ្នែកសម្រាប់ជ្រើសរើស



ត្រួយសម្រាប់បំបៅ



ជើងទំរ



សំអាតផាងស្លឹក



ចិតមែកពូជជាមុខទួរណឺវីស



ច្រៀកដើមសម្រាប់តត្រួយ



ត្រួយសម្រាប់សៀត



ស៊កត្រួយទៅនឹងដើមទំរ



រុំភ្ជាប់





ចងត្រួយជាមួយដើមទំរ





យកថង់ប្លាស្ទិកគ្របពីលើ

**បច្ចេកទេសតត្រួយលើដើមចាស់**

ការតត្រួយដើមចាស់ គឺជាបច្ចេកទេសដែលគេអនុវត្តទៅលើដើមចាស់ដែលមិនផ្តល់ផល ឬ ផ្តល់ផលទាប ។ ដើមដែលមានទិន្នផលទាប ដែលមានអាយុ ៥-២០ ឆ្នាំអាចធ្វើអោយមានទិន្នផលខ្ពស់វិញបានតាមរយៈការបំបៅដើម ។ គេអនុវត្តន៏ការបំបៅដើមចាស់ដោយ ៖

- ជាដំបូងត្រូវកាត់ដើមចាស់ដែលដោយទុកកំពស់ ០,៧៥ - ១ម ពីដី ដោយប្រយ័ត្នជៀសវាងកុំអោយដើមវាបែកសាច់ឈើ បើប្រើរណាអារដើមជាការល្អអនុវត្តនៅខែមិនា-មេសា
- រដូវដែលល្អសម្រាប់តត្រួយនៃដើមចាស់ត្រូវធ្វើនៅខែ ឧសភា-កញ្ញា
- ពន្លកនៃបំពង់ថ្មីនឹងចេញ ៣០-៤៥ ថ្ងៃ បន្ទាប់ពីការកាត់ ផ្នែកលើដើមចោល ។ យើងទុក ៦-៧ នៃបំពង់លាស់ថ្មីក្នុងមួយដើម សម្រាប់ធ្វើការតត្រួយ ។
- រីឯវិធីតត្រួយដូចគ្នានឹងវិធីតត្រួយលើដើមទំរដែរ ។



ការកាត់បំពង់ដែលទើបតែលាស់ថ្មី



ការតត្រួយជាមួយបំពង់ដែលល្អ



ការតត្រួយលើបំពង់ផ្សេងទៀតតែលើដើមតែមួយ



ការខ្ចប់ក្រដាសការពារសំណើមពេលធ្វើការតត្រួយរួច

**តត្រួយលើដើមចាស់**

## ២.១៤ សេដ្ឋកិច្ច

**ការប្រែប្រួលតំលៃលើទីផ្សារ**

តំលៃទិញគ្រាប់ស្វាយចន្ទី គឺប្រែប្រួលទៅតាមតំរូវការរបស់ទីផ្សារវៀតណាម ។ ក្នុងរដូវប្រមូលផល (ខែ មិនា ដល់ ខែ មេសា)ជាទូទៅមានតំលៃខ្ពស់ ព្រោះនៅពេលនោះរោងចក្រកែច្នៃគ្រាប់ស្វាយចន្ទីនៅប្រទេសវៀតណាម មានតំរូវការច្រើន ប៉ុន្តែបន្ទាប់មកតំលៃនោះក៏ថយចុះទៅវិញ ។

**តំលៃគ្រាប់ស្វាយចន្ទី**

តាមការសាកសួរពីលោក គង់ សៀកហោ ម្ចាស់ចំការស្វាយចន្ទីនៅ ស្រុកស្គន់ ខេត្តកំពង់ចាម បានអោយដឹង ថាតំលៃនៃគ្រាប់ស្វាយចន្ទីមានការប្រែប្រួលពី ១ ឆ្នាំ ទៅ ១ ឆ្នាំ គឺនៅ ៖

- ឆ្នាំ ២០០៤ តំលៃគ្រាប់ស្វាយចន្ទី ៧៥០ ទៅ ៨០០ ដុល្លា ក្នុង ១ តោន
- ឆ្នាំ ២០០៥ តំលៃគ្រាប់ស្វាយចន្ទី ១.០០០ ដុល្លា ក្នុង ១ តោន
- ឆ្នាំ ២០០៦ តំលៃគ្រាប់ស្វាយចន្ទី ៦៥០ ដុល្លា ក្នុង ១ តោន

## ការប្រៀបធៀបសេដ្ឋកិច្ចរវាងការដាំតាមទំលាប់ និងប្រើតាមបច្ចេកទេស

តារាងទី ១ ប្រៀបធៀបសេដ្ឋកិច្ចរវាងការដាំតាមទំលាប់ និង ប្រើតាមបច្ចេកទេស

| បរិយាយ | តាមទំលាប់ | | | តាមបច្ចេកទេស | | |
|---|---|---|---|---|---|---|
| | បរិមាណ | តំលៃ(រ) | សរុប(រ) | បរិមាណ | តំលៃ(រ) | សរុប(រ) |
| ១-ការចំណាយរយៈពេល ១០ ឆ្នាំ | | | | | | |
| -ការកាប់ព្រៃ សំអាតដី | ១ ហ.ត | ១៦០.០០០ | ១៦០.០០០ | ១ ហ.ត | ១៦០.០០០ | ១៦០.០០០ |
| -ភ្ជួររាស់ | ១ ហ.ត | ២៥០.០០០ | ២៥០.០០០ | ១ ហ.ត | ២៥០.០០០ | ២៥០.០០ |
| -ពូជ | ៣ គ.ក្រ | ១.៥០០ | ៤៥.០០០ | កូនបំបៅ ១៥៦ ដើម | ២.៤០០ | |
| -ឈ្នួលដាំ | ៤ នាក់ | ៤០.០០០ | ១៦០.០០០ | | ៤០.០០០ | ១៦០,០០០ |
| -ធ្វើស្មៅ | ២ ដង,ឆ្នាំ x ១០ ឆ្នាំ | ៧០.០០០ x ១០ ឆ្នាំ | ៧០០.០០០ | ២ ដង,ឆ្នាំ x ១០ ឆ្នាំ | ៧០.០០០ x ១០ ឆ្នាំ | ៧០០.០០០ |
| -ការដាក់ជី | ០ | ០ | ០ | រយៈពេល ១០ ឆ្នាំ | ១.០២៩.៦០០ | ១.០២៩.៦០០ |
| **សរុប** | | | **១.៣១៥.០០០** | | | **២.៦៧៤.០០០** |
| **២-ប្រាក់ចំណូលរយៈពេល ១០ ឆ្នាំ** | ១.៨៦៥ គ.ក្រ | ២.៧៣០ | ៥.០៩១.៤៥០ | ៣.០៥៨ គ.ក្រ | ២.៧៣០ | ៨.៣៤៨.៣៤០ |
| **៣-ប្រាក់ចំណេញរយៈពេល ១០ ឆ្នាំ** | | | ៣.៧៧៦.៤៥០ | | | ៥.៦៧៤.៣៤០ |
| **៤-ប្រាក់ចំណេញក្នុង ១ ឆ្នាំ** | | | ៣៧៧.៦៤៥ | | | ៥៦៧.៤៣៤ |

## ៣. ការកំណត់តំបន់សម្រាប់ផ្សព្វផ្សាយ(ការផ្សាំ និង បំបៅ)

តំបន់ដែលត្រូវផ្សព្វផ្សាយគឺកន្លែងដែលមានដាំដំណាំស្វាយចន្ទីច្រើន ដូចជាខេត្ត ៖

-កំពង់ចាម

-កំពង់ធំ

-រតនៈគិរី

-មណ្ឌលគិរី

-កំពង់ឆ្នាំង

### ៣.១ អ្នកដែលត្រូវបណ្តុះបណ្តាល

-ជាកសិករដែលមានចំការស្វាយចន្ទី

-សហគមន៍អ្នកដាំដំណាំស្វាយចន្ទី

-កសិករដែលអាចសរសេរ និង អានអក្សរបាន

-កសិករដែលមានពេលវេលាគ្រប់គ្រាន់សម្រាប់ចូលរួមការបណ្តុះបណ្តាល

-ជាកសិករដែលអាចចែករំលែកនូវចំណេះដឹងពីការចូលរួមវគ្គបណ្តុះបណ្តាលទៅកសិករដទៃទៀត

**៣.២ ចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាលក្នុង១ វគ្គ**

ចំនួន ១៥ នាក់ មកពី ខេត្តផ្សេងៗ (ក្នុងមួយខេត្តចំនួន ៣ នាក់)

**៣.៣ សំភារៈសម្រាប់ចំណាយក្នុងការបណ្តុះបណ្តាល និង ការអនុវត្តន៍**

**សំភារៈផ្គត់ផ្គង់ដោយគំរោង**

-ឯកសារដំណាំស្វាយចន្ទីស្តីពី ការជ្រើសរើសដើមដែលមានទិន្នផលខ្ពស់ បច្ចេកទេសបណ្តុះកូន ការផ្សាំ ការបំបៅស្វាយចន្ទី

-បង់រុំប្លាស្ទិក កាំបិតសម្រាប់បំបៅ និង ផ្សាំ

-ថង់បាស្ទិក

**សំភារៈចូលរួមចំណែកពីកសិករ**

-គ្រាប់ស្វាយចន្ទី ជើងទំរ ត្រួយបំបៅ

-បង្គី អាចម៍គោ ដី ផេះអង្កាម ចបកាប់

-កំលាំងពលកម្ម ។

**៣.៤ ពេលវេលា**

-សម្រាប់ដាំកូនក្នុងថង់អនុវត្តន៍នៅក្នុងខែ កុម្ភៈ ដល់ ឧសភា

-សម្រាប់បំបៅ មេសា ដល់ កក្កដា

-សម្រាប់ផ្សាំ គ្រប់ពេលវេលា

**៣.៥ ផែនការវគ្គបណ្តុះបណ្តាល**

**មុនពេលវគ្គបណ្តុះបណ្តាល**

សម្រាប់គ្រូបណ្តុះបណ្តាល

-ជ្រើសរើសទីកន្លែងបណ្តុះបណ្តាលអោយបានសមស្រប (ទីកន្លែង សម្រាប់បង្រៀន និង អនុវត្តន៍)

-រៀបចំឯកសារសម្រាប់ចែកជូនកសិករដែលចូលរួម

-រៀបចំឯកសារសម្រាប់ធ្វើការបង្ហាញ (រូបភាព ទ្រឹស្តី)

-រៀបចំសំភារៈសម្រាប់ធ្វើការអនុវត្តន៍ និង ចេះអនុវត្តន៍ដោយខ្លួនឯងផង

**សម្រាប់កសិករដែលចូលរួមវគ្គបណ្តុះបណ្តាល**

-កសិករត្រូវជ្រើសរើសសម្រាប់ចូលវគ្គបណ្តុះបណ្តាលអោយបានមុនខែកុម្ភៈ

-កសិករដែលចូលរួមត្រូវត្រៀមគ្រាប់ពូជស្វាយចន្ទី ល្បាយដីដែលលាយរួច (ដី លាមកគោ ផេះអង្កាម) ច្រកទៅក្នុងថង់ប្លាស្ទិក ដើម្បីបណ្តុះកូនធ្វើជាជើងទំរ សម្រាប់យកទៅបំបៅនៅវគ្គបណ្តុះបណ្តាល(ក្នុងកសិករម្នាក់ត្រូវបណ្តុះកូនអោយបាន ៥០ ដើម) ។

-កសិករត្រូវជ្រើសរើសដើមដែលមានទិន្នផលខ្ពស់សម្រាប់យកត្រួយមកបំបៅ និង ផ្សាំ

**ដំណើរការវគ្គបណ្តុះបណ្តាល**

-ថ្ងៃទី ១ បង្រៀនទ្រឹស្តីស្តីពី ការជ្រើសរើសដើមដែលមានទិន្នផលខ្ពស់ ការជ្រើសរើសត្រួយសម្រាប់បំបៅ បច្ចេកទេសបណ្តុះកូន ផ្សាំ និង បំបៅ

-ថ្ងៃទី ២ ការបង្ហាញរបស់អ្នកបច្ចេកទេសទៅលើការជ្រើសរើសដើមដែលមានទិន្នផលខ្ពស់សម្រាប់ធ្វើការផ្សាំ និង ការអនុវត្តន៍ផ្ទាល់របស់កសិករ

-ថ្ងៃទី ៣ ការបង្ហាញរបស់អ្នកបច្ចេកទេសទៅលើការជ្រើសរើសដើមដែលមានទិន្នផលខ្ពស់សម្រាប់យកត្រួយមកបំបៅនៅលើដើមខ្ចី និង ដើមចាស់ និង ការអនុវត្តន៍ផ្ទាល់របស់កសិករ

## ៣.៦ ការចំណាយទៅលើសំភារៈ និងការចំណាយផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាល

**តារាងទី ២ ការចំណាយទៅលើសំភារៈ**

| ល.រ | មុខចំណាយ | ឯកតា | បរិមាណ | តំលៃ (ដុល្លា) | សរុប(ដុល្លា) |
|---|---|---|---|---|---|
| ១ | ឯកសារដំណាំស្វាយចន្ទី | សន្លឹក | ៤៥០ | ០,០១២៥ | ៥,៦២៥ |
| ២ | កាំបិតសម្រាប់បំបៅ | ផ្លែ | ១៥ | ១,២៥ | ១៨,៧៥ |
| ៣ | បង់រុំប្លាស្ទិក | ដុំ | ១៥ | ១ | ១៥ |
| ៤ | ថង់ប្លាស្ទិក | គ.ក្រ | ០,៥ | ១,៧៥ | ០,៨៧៥ |
| | សរុប | | | | **៤០,២៥** |

**តារាងទី ៣ ការចំណាយផ្សេងៗក្នុងពេលបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃ**

| ល.រ | បរិយាយ | ចំណាយ |
|---|---|---|
| ១ | ប្រាក់ឧបត្ថម្ភសម្រាប់ភ្នាក់ងារផ្សព្វផ្សាយ | ២ នាក់ x ៣ ថ្ងៃ x ១០ ដុល្លា = ៦០ ដុល្លា |
| ២ | ភេសជ្ជៈ និង អាហារសម្រន់ | ១៥ នាក់ x ៣ ថ្ងៃ x ១ ដុល្លា = ៤៥ ដុល្លា |
| ៣ | អាហារថ្ងៃត្រង់ | ១៥ នាក់ x ៣ ថ្ងៃ x ១ ដុល្លា = ៤៥ ដុល្លា |
| ៤ | ថ្លៃធ្វើដំណើរ អាស្រ័យទៅតាមទីកន្លែង | ២ នាក់ x ២ ដង x .......... = .......ដុល្លា |
| | សរុប | ................ ដុល្លា |

### ៣.៧ សកម្មភាពត្រួតពិនិត្យ និង វាយតំលៃ

ជំហានដំបូង យើងចុះទៅធ្វើការជ្រើសរើសកសិករមកបណ្តុះបណ្តាល ព្រមទាំងអង្កេតស្ថានភាពរបស់គាត់ ជំហានទីពីរយើងចាប់ផ្តើមធ្វើការបណ្តុះបណ្តាល ជំហានទីបីគឺបន្ទាប់ពីការបណ្តុះបណ្តាល អ្នកផ្សព្វផ្សាយមិនទាន់បញ្ចប់ការងារជាមួយកសិករនៅឡើយទេ។ យើងនៅមានការតាមដានពិនិត្យ និង វាយតំលៃនូវអ្វីដែលគាត់បានទទួលពី យើង។ បន្ទាប់ពីការបណ្តុះបណ្តាលបាន រយៈពេលពី ២ ខែ ទៅ ៣ ខែ យើងគួរអញ្ជើញកាត់មកជុំគ្នាម្តងទៀត ដើម្បីសាកសួរពីចំណេះដែលយើងបានផ្តល់អោយគាត់ តើគាត់បានបង្កើតសកម្មភាពអ្វីខ្លះបន្ទាប់ពីរៀនជាមួយយើង។ បន្ទាប់មកទៀតយើងចុះផ្ទាល់ទៅទីកន្លែង ចំការ ឬ ផ្ទះរបស់គាត់ម្តង ថាតើគាត់បានធ្វើមែន ឬ មិនមែន។

**បញ្ហាក់** សកម្មភាពខ្លះគាត់មិនទាន់អាចធ្វើបានដោយសារៈ

-ពេលវេលាមិនទាន់មកដល់

-គាត់ពុំមានលទ្ធភាពគ្រប់គ្រាន់

-គាត់អាចមានរវល់ ឬ បញ្ហានៅក្នុងគ្រួសាររបស់គាត់

### ឯកសារយោង


១ សែ សុភី ១៩៩៦ , ដំណាំស្វាយចន្ទីនៅកម្ពុជា

២ សុខ វណ្ណនី ១៩៩៦ , ផលិតកម្មដំណាំស្វាយចន្ទីរបស់ក្រុមហ៊ុនអាគ្រូស្តារនៅស្រុកជើងព្រៃខេត្តកំពង់ចាម

៣ ប៉ែន វិចិត្រ ២០០៣ , ដំណាំស្វាយចន្ទីជាលក្ខណៈគ្រួសារនៅស្រុកមេមត់ខេត្តកំពង់ចាម

៤ Dr.Varanashi krishna Moorthy, 2006 , Organic Cashew cultivation Practices

៥ Cashew by J GOhler,KIT, ISBN 9068320742, 1988

៦ Food Chain : The International Journal of Small Scale Food Processing, Number 28 May 2001 Special issue dedicated to cashew processing and Marketing, ITDG

៧ Food Chain : The International Journal of Small Scale Food Processing, Number 24 May 1999 Empowering Small Scale cashew processors in Sri Lanka, ITDG

៨ Processing Manuals For Non Literate Farmer, Hand Book for Development Workers

៩ The Cambodian Cashew Industry Andrew McNaughton & Associates Phnom Penh September 2005

១០ Cashew as an Agro-industry Crop Prospects and Potentials, RÜDIGER BEHERENS 1996

១១ Cashew Production and Processing Technology, Dr. R. C. Mandal 2000.

១២ Cashew Production Technology, Dr. M. Gopalakrishna Bhat, 2003

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:**
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ២០០ វិថីព្រះនរោត្តម ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: ០១២ ៨៣៣ ៧៧៧ ឬ ០១២ ៨២៦ ៦១៧
ទូរសារ: ៨៥៥ ២៣ ២១០ ៩៤៨ ឬ ៨៥៥ ២៣ ២១៣ ០១១
អ៊ីម៉ែល: kunso@camnet.com.kh ឬ mak_soeun@camnet.com.kh